អង្គការសហប្រជាជាតិ

A/HRC/24/63

**មហាសន្និបាត**

ចែកចាយ : ទូទៅ
៥ សីហា ២០១៣

អត្ថបទដើម ៖ អង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
**សម័យប្រជុំលើកទីម្ភៃបួន**
**របៀបវារៈចំណុចទី១០**
**ការជួយឧបត្ថម្ភផ្នែកបច្ចេកទេស និងការកសាងសមត្ថភាព**

# របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាព សិទ្ធិមនុស្សនៅកម្ពុជា លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី

*សេចក្តីសង្ខេប*

ដោយបានធ្វើរបាយការណ៍សំខាន់ធំៗចំនួនបួន ដែលមានការវិភាគគ្រប់ជ្រុងជ្រោយអំពីស្ថានភាពសិទ្ធិមនុស្ស និងបញ្ហាប្រឈមដែលព្រះរាជាណាចក្រកម្ពុជាកំពុងជួបប្រទះ ក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ចាប់តាំងពីលោកទទួលបានការតែងតាំងពីក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិក្នុងខែមីនា ឆ្នាំ២០០៩ អ្នករាយការណ៍ពិសេសបានផ្តោតទៅលើដំណើរបេសកកម្មពីរចុងក្រោយរបស់លោកមកកាន់ប្រទេសនេះ ដែលបេសកកម្មមួយបានធ្វើឡើងនៅក្នុងខែធ្នូ ឆ្នាំ២០១២ និងបេសកកម្មមួយទៀត ធ្វើឡើងនៅខែឧសភា ឆ្នាំ២០១៣  ស្តីពីការតាមដានការអនុវត្តអនុសាសន៍ដែលបានលើកឡើងនៅក្នុងរបាយការណ៍របស់លោក និងដើម្បីត្រួតពិនិត្យមើលស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។ របាយការណ៍ប្រចាំឆ្នាំកន្លងមករបស់លោកដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស បានផ្តោតលើកំណែទម្រង់ប្រព័ន្ធតុលាការ សភា និងការបោះឆ្នោត និងលើផលប៉ះពាល់សិទ្ធិមនុស្សដោយសារសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត។ របាយការណ៍របស់លោកបានបញ្ចូលជាបន្តបន្ទាប់នូវអនុសាសន៍ទាំងឡាយដែលបានធ្វើឡើង ដើម្បីជួយដល់រដ្ឋាភិបាលក្នុងការអនុវត្តរបៀបវារៈកំណែទម្រង់ និងដំណើរការលទ្ធិប្រជាធិបតេយ្យនីយកម្មក្នុងប្រទេសនេះ។ ជាជាងការទទួលយករឿងសិទ្ធិមនុស្សថ្មី លោកបានចាត់ទុកថា  វាដល់ពេលវេលាមួយសមស្របក្នុងការពិនិត្យតាមដានអំពីវឌ្ឍនភាពលើការអនុវត្តអនុសាសន៍ ដែលបានធ្វើនៅក្នុងរបាយការណ៍កន្លងមករបស់លោក។

ការទទួលស្វាគមន៍ដែលអ្នករាយការណ៍ពិសេស បានទទួលពីរាជរដ្ឋាភិបាលក្នុងអំឡុងពេលនៃដំណើរបេសកកម្មលើកដំបូងរបស់លោកមកកាន់ប្រទេសនេះក្នុងខែធ្នូ ឆ្នាំ២០១២ គឺជាបេសកកម្មមួយសោះកក្រោះ ដែលនៅក្នុងអំឡុងពេលនោះ មិនមានសមាជិកជាន់ខ្ពស់ណាម្នាក់របស់រដ្ឋាភិបាលជួបលោកឡើយ។ បន្ទាប់ពីការបោះពុម្ពផ្សាយរបាយការណ៍ធំៗពីរ ដោយអ្នករាយការណ៍ពិសេស ដែលក្នុងនោះមានរបាយការណ៍មួយស្តីពីកំណែទម្រង់ការបោះឆ្នោត និងមួយផ្សេងទៀត ស្តីពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត លោកបានទទួលរងនូវពាក្យសំដីមិនគួរគប្បីមួយចំនួនសំដៅមកលើរូបលោកផ្ទាល់។ នេះគឺជាទង្វើដែលគួរឲ្យសោកស្តាយជាខ្លាំង ពីព្រោះថាកិច្ចពិភាក្សារវាងអ្នករាយការណ៍ពិសេស និងរដ្ឋាភិបាល គួរតែផ្តោតយ៉ាងមុតមាំទៅលើខ្លឹមសារការងារដែលអង្គការសហប្រជាជាតិបានប្រគល់អាណត្តិឱ្យលោកដោយមិនត្រូវផ្តោតលើរូបលោកជាលក្ខណៈបុគ្គលឡើយ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានសហការជាមួយលោក ក្នុងអំឡុងពេលនៃដំណើរបេសកកម្មរបស់លោកមកកាន់ប្រទេសនេះ ក្នុងខែឧសភា ឆ្នាំ២០១៣ នៅពេលដែលលោកបានជួបជាមួយតួអង្គជាច្រើន។ តួអង្គទាំងនោះរួមមាន សមាជិកជាន់ខ្ពស់របស់រដ្ឋាភិបាលដែលបានត្រៀមផ្តល់ជូនលោកនូវព័ត៌មានផ្សេងៗ បានត្រៀមទទួលស្គាល់ភាពខ្វះខាត ដែលកើតមាន និងមានឆន្ទៈក្នុងការធ្វើការជាមួយអ្នករាយការណ៍ពិសេសក្នុងន័យស្ថាបនា ដើម្បីដោះស្រាយបញ្ហាប្រឈមដែលនៅសេសសល់ទាក់ទងនឹងការការពារសិទ្ធិមនុស្សបានល្អប្រសើរជាងមុន លទ្ធិប្រជាធិបតេយ្យរឹងមាំថែមទៀត និងនីតិរដ្ឋពិតប្រាកដក្នុងប្រទេសកម្ពុជា។ លោកមានការពេញចិត្តនឹងកម្រិតនៃការចូលរួម និងកិច្ចពិភាក្សាជាមួយដៃគូពិភាក្សារបស់រដ្ឋាភិបាល ដោយសារកិច្ចពិភាក្សានេះបានធ្វើឡើងដោយមានស្មោះត្រង់ ស្និទ្ធស្នាល និងក្នុងន័យស្ថាបនា។

ទន្ទឹមនឹងមានកិច្ចប្រជុំលក្ខណៈឯកជនជាមួយនឹងសមាជិកជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ប្រព្រឹត្តទៅក្នុងន័យស្ថាបនា អ្នករាយការណ៍ពិសេសមានការសោកស្តាយ ដោយសារលោកត្រូវបានទទួលរងនូវឧប្បត្តិហេតុអសកម្មមួយចំនួនក្នុងអំឡុងពេលនៃដំណើរបេសកកម្មរបស់លោក។ ប្រសិនបើមើលរបាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយឧប្បត្តិហេតុទាំងនោះត្រូវបានគេរៀបចំឡើង ដើម្បីបំភិតបំភ័យ និងយាយីរំខានដល់អ្នករាយការណ៍ពិសេស ក្នុងគោលបំណងបង្វែរការយកចិត្តទុកដាក់របស់លោកលើបញ្ហាសំខាន់ៗមួយចំនួន។ លោកបានទទួលរងផងដែរ នូវការចោទប្រកាន់គ្មានមូលដ្ឋានអំពីភាពអគតិចំពោះរាជរដ្ឋាភិបាល។ ទាំងអស់នេះគឺជាការរិះគន់ស្រដៀងៗគ្នាជាខ្សែសង្វាក់ចំពោះការងាររបស់អ្នករាយការណ៍ពិសេស និងមិនមានអ្វីដែលខុសប្លែកគ្នាខ្លាំងពីការប្រព្រឹត្តទៅលើអ្នករាយការណ៍ពិសេសមុនៗ កាលពីពេលកន្លងមកនោះទេ។ បើទោះជាលោកជួបប្រទះបទពិសោធន៍ដ៏ជូរចត់បែបនេះក្តី វាមិនបានធ្វើឲ្យអ្នករាយការណ៍ពិសេសងាករេចេញពីគោលដៅនៃអាណត្តិរបស់លោកឡើយ ហើយលោកនៅតែបន្តធ្វើការតស៊ូមតិសម្រាប់របៀបវារៈកំណែទម្រង់ស្ថាប័នជាតិដែលទទួលខុសត្រូវក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្សឲ្យបោះជំហានទៅមុខទៀត។ តាមពិតជាប្រតិកម្មទៅនឹងឧប្បត្តិហេតុទាំងនេះ លោកបានទទួលនូវសារសំដែងគាំទ្រដល់ការងាររបស់លោក នៅក្នុងប្រទេសកម្ពុជាយ៉ាងច្រើនសន្ធឹកសន្ធាប់ពីមនុស្សម្នាគ្រប់ស្រទាប់ក្នុងសង្គម ដែលនេះគឺជាការលើកទឹកចិត្តយ៉ាងខ្លាំងដល់រូបលោក។ ក្រៅពីដៃគូពិភាក្សារបស់រដ្ឋាភិបាល អ្នករាយការណ៍ពិសេសក៏បាន ប្រាស័យទាក់ទងផងដែរជាមួយភាគីពាក់ព័ន្ធដទៃទៀតក្នុងសង្គមកម្ពុជា រួមមាន គណបក្សនយោបាយ សង្គមស៊ីវិល សហគមន៍មូលដ្ឋាន ប្រជាពលរដ្ឋឯកជន និង

ដៃគូអភិវឌ្ឍប្រទេសកម្ពុជា។

ជារួមមក កម្ពុជាហាក់ដូចជាកំពុងតែធ្វើដំណើរនៅលើផ្លូវមួយឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យ។ វាគឺជាដំណើរផ្លូវមួយដ៏វែងឆ្ងាយ ចាប់តាំងពីមានការចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១ និងការអនុម័តរដ្ឋធម្មនុញ្ញថ្មី ដែលបានបង្កើតឡើងតាមគោលការណ៍ប្រជាធិបតេយ្យសេរី នៅក្នុងឆ្នាំ ១៩៩៣។ វិធានការធំៗមួយចំនួន ដែលត្រូវបានធ្វើឡើងក្នុងទិសដៅវិជ្ជមាននៅក្នុងអំឡុងពេលនៃការ ពិនិត្យរបាយការណ៍ រួមមាន ការដោះលែង លោក ម៉ម សូណង់ដូ ដែលជាអ្នកការពារសិទ្ធិមនុស្សដ៏ល្បី ឈ្មោះមួយរូប និងការលើកលែងទោសដល់ថ្នាក់ដឹកនាំគណបក្សប្រឆាំង គឺ លោក សម រង្ស៊ី ដែលត្រូស ត្រាយផ្លូវឲ្យគាត់ វិលត្រឡប់មកប្រទេសកម្ពុជាវិញ ពីការរស់នៅនិរទេសខ្លួននៅប្រទេសបារាំង ដើម្បីចូលរួម ក្នុងដំណើរការនយោបាយនៅប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជានៅតែត្រូវធ្វើ ដំណើរទៅមុខទៀត ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស ពង្រឹងអភិបាលកិច្ចល្អ ពង្រឹងឯករាជ្យភាព និងសមត្ថភាពរបស់ ស្ថាប័នរដ្ឋដែលទទួលខុសត្រូវក្នុងការលើកស្ទួយសិទ្ធិប្រជាពលរដ្ឋ ដូចដែលដៃគូ ពិភាក្សារបស់រដ្ឋាភិបាល បានទទួល ស្គាល់នៅក្នុងដំណើរបេសកកម្មរបស់អ្នករាយការណ៍ពិសេសមកកាន់ ប្រទេសកម្ពុជា ក្នុងខែឧសភា ឆ្នាំ២០១៣។ លោកបានឃើញសញ្ញាវិកចម្រើនដែលរដ្ឋាភិបាលបានទទួល យកចំណុចខ្វះខាត យ៉ាងឆាប់រហ័ស នៅក្នុងកិច្ចប្រជុំរបស់លោកជាមួយនឹងពួកគេ ដោយបានបង្ហាញពី ឆន្ទៈរបស់គេក្នុងការធ្វើ ការជាមួយលោក ក្នុងការខិតខំព្យាយាមរបស់គេ ដើម្បីធ្វើឱ្យប្រសើរឡើងនូវ ស្ថានភាពសិទ្ធិមនុស្សសម្រាប់ប្រជាជនកម្ពុជា។ ទន្ទឹមនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងអំ ពីលទ្ធិប្រជាធិបតេយ្យសេរី ប៉ុន្តែក្នុងស្ថានភាពជាក់ស្តែង វាប្រហាក់ប្រហែលទៅនឹងលទ្ធិប្រជាធិបតេយ្យមួយ ដែលមានកម្រិតក្នុងទិដ្ឋភាពជា ច្រើនទៅវិញ។ ប្រទេសនេះមានកន្លែងខ្លះត្រូវដើរស្របតាមបទដ្ឋានសិទ្ធិ មនុស្សអន្តរជាតិ ដែលកើតចេញពីសន្ធិសញ្ញាសិទ្ធិមនុស្សទាំងឡាយ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន ដោយស្ម័គ្រចិត្ត ហើយបាននិង កំពុងខិតខំព្យាយាមធ្វើឲ្យសម្រេចគោលដៅនេះ។

សហគមន៍អន្តរជាតិបានដាក់ទុនយ៉ាងច្រើនក្នុងប្រទេសកម្ពុជា ចាប់តាំងពីមានការចុះកិច្ចព្រម ព្រៀងសន្តិភាពទីក្រុងប៉ារីស និងការបោះឆ្នោតបែបប្រជាធិបតេយ្យ ដែលបានធ្វើឡើងជាលើកដំបូងក្រោម ការឧបត្ថម្ភពីអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ហៅកាត់ថា អ៊ុនតាក់ នៅឆ្នាំ១៩៩៣។ បំណងប្រាថ្នារបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស និងតួអង្គជាតិទាំង ឡាយ ដែលបានចូលរួមក្នុងសន្និសីទសន្តិភាពទីក្រុងប៉ារីស គឺចង់ឃើញប្រទេសកម្ពុជាមានការអភិវឌ្ឍតាម បែបប្រជាធិបតេយ្យសេរី។ អ្នករាយការណ៍ពិសេស មើលឃើញពីតួនាទីរបស់សហគមន៍អន្តរជាតិ រាប់ទាំង អាណត្តិរបស់លោកផងដែរ ក្នុងការជួយដល់ប្រជាជន និងរដ្ឋាភិបាលកម្ពុជា នៅក្នុងការធ្វើដំណើរឆ្ពោះទៅ រកលទ្ធិប្រជាធិបតេយ្យសេរីពេញលេញជាងនេះថែមទៀត ដែលបានបញ្ជាក់អះអាងតាមរយៈសន្តិភាព ប្រកបដោយនិរន្តរភាព និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌។ ដូចដែលនឹងឃើញតាមការ បរិយាយពីសមិទ្ធផលដែលសម្រេចបាន ក្នុងការអនុវត្តអនុសាសន៍របស់លោកនៅក្នុងរបាយការណ៍នេះ ខណៈដែលអនុសាសន៍មួយចំនួនរបស់លោកទំនងជាបាននិងកំពុងអនុវត្ត អនុសាសន៍មួយចំនួនផ្សេង ទៀតទំនងជាត្រូវស្ថិតក្រោមការពិចារណាយ៉ាងសកម្មសម្រាប់ការអនុវត្ត។ ទាំងនេះគឺជាសញ្ញាគួរជាទីលើក

ទឹកចិត្ត ហើយរាជរដ្ឋាភិបាលកម្ពុជា គួរតែបានទទួលការកោតសរសើរចំពោះសមិទ្ធផលទាំងនេះ។ ទន្ទឹមពេលដែលដំណើរការកំណែទម្រង់ប្រព័ន្ធតុលាការ សភា និងការបោះឆ្នោត មានសន្ទុះយឺត រដ្ឋាភិបាលនៅមិនទាន់មានចំណាត់ការអនុវត្តអនុសាសន៍ភាគច្រើនទាក់ទងនឹងការផ្តល់ និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងទៀតនៅឡើយ។ ដូចធ្លាប់មានកន្លងមកដែរ ស្ថិតក្នុងបរិបទនេះ លោកបានត្រៀមខ្លួនជាស្រេច ដើម្បីជួយដល់រដ្ឋាភិបាលកម្ពុជា។ ដោយចងចាំក្នុងចិត្ត លោកជំរុញឱ្យរាជរដ្ឋាភិបាលពន្លឿនដំណើរការកំណែទម្រង់តាមការសន្យានូវស្ថាប័នរដ្ឋដែលទទួលខុសត្រូវក្នុងការការពារ និងការលើកស្ទួយសិទ្ធិមនុស្សនិងពន្លឿនដំណើរការប្រជាធិបតេយ្យនីយកម្មរបស់ប្រទេសកម្ពុជា ដើម្បីឲ្យអត្ថប្រយោជន៍ដែលកើតចេញពីកំណើនសេដ្ឋកិច្ច អាចត្រូវបានធ្វើការចែករំលែកប្រកបដោយសមធម៌ដល់ប្រជាពលរដ្ឋគ្រប់រូបនៅក្នុងប្រទេសនេះ។

## មាតិការឿង


| | កថាខ័ណ្ឌ | ទំព័រ |
|---|---|---|
| I. សេចក្តីផ្តើម ---------- | ១ - ៦ | ៦ - ៨ |
| II. លិខិតដែលបានផ្ញើជូនរដ្ឋាភិបាល៧ ---------- | ៧ - ១៣ | ៨ - ១១ |
| III. ការតាមដានការអនុវត្តអនុសាសន៍ស្តីពីប្រព័ន្ធតុលាការ ---------- | ១៤ - ២៨ | ១១- ១៤ |
| IV. ការតាមដានការអនុវត្តអនុសាសន៍ស្តីពីសភា ---------- | ២៩ - ៣២ | ១៤ - ១៦ |
| V. ការតាមដានការអនុវត្តអនុសាសន៍ស្តីពីប្រព័ន្ធបោះឆ្នោត ---------- | ៣៣- ៤៧ | ១៦ - ២៣ |
| VI. ការតាមដានការអនុវត្តអនុសាសន៍ស្តីពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត ---------- | ៤៨- ៥៩ | ២៣ - ២៧ |
| VII. សេចក្តីសន្និដ្ឋាន ---------- | ៦០- ៦៤ | ២៧ - ២៩ |
| VIII. អនុសាសន៍---------- | ៦៥- ៧៥ | ២៩ - ៣០ |

## I. សេចក្តីផ្តើម

១. នេះជារបាយការណ៍លើទីប្រាំរបស់អ្នករាយការណ៍ពិសេសបច្ចុប្បន្ន ស្តីពីស្ថានភាពសិទ្ធិមនុស្ស នៅប្រទេសកម្ពុជា ដែលបានដាក់ជូនស្របតាមសេចក្តីសម្រេចលេខ១៨/២៥ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។

២. នៅក្នុងអំឡុងឆ្នាំស្ថិតក្រោមការពិនិត្យឡើងវិញនេះ អ្នករាយការណ៍ពិសេសបានបន្តត្រួតពិនិត្យ ស្ថានភាពសិទ្ធិមនុស្សក្នុងព្រះរាជាណាចក្រកម្ពុជា។ លោកបានបន្តទទួលព័ត៌មានស្តីពីស្ថានភាពសិទ្ធិមនុស្សពី ភាគីពាក់ព័ន្ធផ្សេងៗក្នុងប្រទេសកម្ពុជា រាប់ទាំងរដ្ឋាភិបាល គណបក្សប្រឆាំង អង្គការសង្គមស៊ីវិល និងប្រជា ពលរដ្ឋឯកជន ដែលក្នុងនោះមានប្រជាពលរដ្ឋខ្លះបានស្វែងរកជំនួយពីអ្នករាយការណ៍ពិសេស ក្នុងការដោះ ស្រាយបញ្ហារំលោភសិទ្ធិមនុស្សនៅក្នុងប្រទេស។ អ្នករាយការណ៍ពិសេសបានបំពេញទស្សនកិច្ចចំនួនពីរ លើកមកកាន់ប្រទេសកម្ពុជានៅក្នុងអំឡុងពេលនៃការពិនិត្យឡើងវិញនេះ ពោលគឺលើកទីមួយ ក្នុងខែធ្នូ ឆ្នាំ ២០១២ និងមួយលើកទៀត នៅខែឧសភា ឆ្នាំ២០១៣។ ខណៈពេលដែលរដ្ឋាភិបាលបានបន្តកិច្ចសហប្រតិ បត្តិការទៀងទាត់ជាមួយអ្នករាយការណ៍ពិសេសឡើងវិញ ហើយលោកបានមានលទ្ធភាពជួបប្រជុំជាមួយតួ អង្គជាច្រើនក្នុងជួររាជរដ្ឋាភិបាល នៅក្នុងខែឧសភា ឆ្នាំ២០១៣ អ្នករាយការណ៍ពិសេស មានការសោកស្តាយ ចំពោះភាពខ្វះខាតផ្នែកព័ត៌មាន ដែលកើតចេញពីការបដិសេធរបស់រដ្ឋាភិបាល ក្នុងការជួបប្រជុំជាមួយលោក ក្នុងខែធ្នូ ឆ្នាំ២០១២។ សរសរគ្រឹះសំខាន់ៗចំពោះការងារជាអ្នករាយការណ៍ពិសេស គឺឯករាជ្យភាព ភាពមិន លំអៀង និងឈរលើកត្តាសត្យានុម័ត។ ដើម្បីសម្រេចគោលដៅនេះ វាជាការចាំបាច់ ក្នុងការបំពេញអាណត្តិ របស់លោកជាអ្នករាយការណ៍ពិសេស មានឱកាសប្រាស័យទាក់ទងជាមួយមនុស្សគ្រប់ស្រទាប់ក្នុងសង្គម កម្ពុជា ដោយគ្មានការរើសអើងឡើយ។ ឱកាសដែលបានខកខានសម្រាប់ការពិភាក្សាជាមួយរាជរដ្ឋាភិបាល គឺពិតជាឱកាសមួយដែលមានសារៈសំខាន់ខ្លាំងណាស់ ជាពិសេសដោយសារគោលដៅនៃការបំពេញបេសក កម្មទាំងពីរនេះ គឺដើម្បីធ្វើការពិនិត្យអំពីវឌ្ឍនភាពដែលសម្រេចបានក្នុងការអនុវត្តអនុសាសន៍ដែលអ្នករាយ ការណ៍ពិសេសបានធ្វើឡើងនៅក្នុងរបាយការណ៍កន្លងមក និងដើម្បីរួមគ្នាកំណត់អំពីវិធីសាស្ត្រប្រសើរបំផុត ដើម្បីដោះស្រាយបញ្ហាប្រឈមដែលនៅសេសសល់។ ស្ថិតក្នុងបរិបទនេះ អ្នករាយការណ៍ពិសេសដាក់របាយ ការណ៍នេះទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស។

៣. ក្នុងអំឡុងពេលបំពេញបេសកកម្មរបស់លោកមកកាន់ប្រទេសកម្ពុជា ក្នុងខែឧសភា ឆ្នាំ២០១៣ អ្នករាយការណ៍ពិសេស បានជួបប្រជុំជាមួយតួអង្គជាច្រើនក្នុងជួររដ្ឋាភិបាល គណបក្សនយោបាយផ្សេងទៀត សង្គមស៊ីវិល និងដៃគូអភិវឌ្ឍប្រទេសកម្ពុជា។ លោកបានជួបជាមួយសមាជិកជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ជាពិសេសជាមួយ លោក ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ឱម យ៉ិនទៀង ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា លោក អ៊ឹម សួស្តី ប្រធានគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត លោក ឈាង វុន ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនា និងព័ត៌មាននៃរដ្ឋសភា លោក អ៊ុំ សារិទ្ធ អគ្គលេខា-ធិការនៃព្រឹទ្ធសភា និងលោក ព្រហ្ម សិទ្ធត្រា រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌។ អ្នករាយការណ៍ពិសេសមានសេចក្តីរីករាយជាខ្លាំងចំពោះការចូលរួម និង កិច្ចពិភាក្សាក្នុងន័យស្ថាបនារបស់លោកជាមួយឥស្សរជនទាំងនេះ។ ក្នុងអំឡុងពេលនៃជំនួបប្រជុំជាមួយអ្នក រាយការណ៍ពិសេស លោក ឱម យ៉ិនទៀង ទេសរដ្ឋមន្ត្រីនិងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បាន

ផ្ដល់ជូនអ្នករាយការណ៍ពិសេសនូវឯកសារគ្មានចុះកាលបរិច្ឆេទ ដែលបញ្ជាក់ថាជាការឆ្លើយតបនឹងការពន្យល់របស់រដ្ឋាភិបាលចំពោះបញ្ហាមួយចំនួន ដែលមានក្នុងរបាយការណ៍មុនៗរបស់អ្នករាយការណ៍ពិសេស។ ឯកសារនេះ មិនធ្លាប់ដែលបានបញ្ជូនដោយរដ្ឋាភិបាលទៅអ្នករាយការណ៍ពិសេសទេ ដូច្នេះលោកមានសេចក្តីរីករាយដែលទទួលបានឯកសារ ដែលអាចឲ្យលោកយល់អំពីជំហររបស់រដ្ឋាភិបាលលើបញ្ហាសិទ្ធិមនុស្សមួយចំនួនដែលកម្ពុជាកំពុងប្រឈម។ ទន្ទឹមនឹងជួយឲ្យយល់ពីជំហររបស់រដ្ឋាភិបាល ការឆ្លើយតបរបស់រដ្ឋាភិបាល មិនមានការផ្លាស់ប្តូរជាដំកំភួនទៅលើការវិភាគដែលអ្នករាយការណ៍ពិសេសបានបង្ហាញក្នុងរបាយការណ៍ ឬអនុសាសន៍ដែល មាននៅក្នុងរបាយការណ៍របស់លោកនោះទេ។

៤. និយាយជាទូទៅ ប្រទេសកម្ពុជានៅតែបន្តធ្វើបានល្អលើសូចនាករមួយចំនួនខាងសេដ្ឋកិច្ច ដែលបានគាំទ្រដោយស្ថិរភាពនយោបាយ។ ប្រទេសនេះហាក់កំពុងស្ថិតលើដំណើរផ្លូវមួយឆ្ពោះទៅសម្រេចបានគោលដៅមួយចំនួននៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ ដោយការសោយទីវង្គតរបស់ព្រះមហាវីរក្សត្រ ព្រះវរបិតា សម្តេចព្រះនរោត្តម សីហនុ នៅក្នុងខែតុលា ឆ្នាំ២០១២ ដែលព្រះអង្គបានបំពេញព្រះរាជបូជនីយកិច្ចយ៉ាងសំខាន់ ក្នុងការរក្សាឯករាជ្យភាព និងការពារបូរណភាពទឹកដីកម្ពុជា ឆ្លងកាត់សម័យកាលដ៏លំបាកបំផុតនៅក្នុងប្រវត្តិសាស្ត្រទំនើបនេះ ប្រទេសនេះបានឈានចូលក្នុងយុគសម័យថ្មី។ អ្នករាយការណ៍ពិសេសបានចូលព្រះបរមរាជវាំង ដើម្បីគោរពវិញ្ញាណក្ខន្ធអតីតព្រះមហាវីរក្សត្រជាលើកចុងក្រោយ នៅក្នុងអំឡុងពេលបំពេញបេសកកម្មរបស់លោកនៅកម្ពុជា ក្នុងខែធ្នូ ឆ្នាំ២០១២ និងបានសំដែងទស្សនៈថា រយៈពេលកាន់ទុក្ខនៃការសោយទីវង្គតនៃព្រះមហាវីរក្សត្រ ព្រះវរបិតា ក៏ជាឱកាសមួយ ដើម្បីរំលឹកអំពីស្នាព្រះហស្ថរបស់ព្រះអង្គកាលដែលព្រះអង្គទ្រង់នៅមានព្រះជន្មនៅឡើយ ក្នុងការទាមទារសន្តិភាព ស្ថិរភាព សម្រុះសម្រួលផ្នែកនយោបាយ ប្រជាធិបតេយ្យ នីតិរដ្ឋ និងសិទ្ធិមនុស្ស និងសមិទ្ធផលដែលកម្ពុជាសម្រេចបាន តាំងពីមានការចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសក្នុងឆ្នាំ១៩៩១។ នេះគឺជារយៈពេលមួយដែលត្រូវពិនិត្យដោយយកចិត្តទុកដាក់ និងបង្ហាញឲ្យឃើញអំពីវិធីដោះស្រាយថ្មី ដើម្បីឈានទៅមុខ ក្នុងភាពសុខដុម និងការបង្រួបបង្រួមជាតិដើម្បីភាពប្រសើរខ្លាំងឡើងថែមទៀតនៃប្រទេសកម្ពុជា។

៥. ចាប់តាំងពីលោកត្រូវបានតែងតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩ អ្នករាយការណ៍ពិសេសបានធ្វើរបាយការណ៍ធំៗសំខាន់ៗចំនួនបួន ដែលរបាយការណ៍នីមួយៗបានធ្វើការវិភាគគ្រប់ជ្រុងជ្រោយអំពីស្ថានភាពសិទ្ធិមនុស្ស ហើយបានដាក់ចេញជាអនុសាសន៍ក្នុងន័យស្ថាបនាជាបន្តបន្ទាប់ ក្នុងគោលដៅជួយដល់រដ្ឋាភិបាល ក្នុងការអនុវត្តរបៀបវារៈកំណែទម្រង់ និងដំណើរការប្រជាធិបតេយ្យនីយកម្មក្នុងប្រទេសកម្ពុជា។ ប៉ុន្តែទោះជាមានការរីកចម្រើនក្នុងវិស័យមួយចំនួនហើយក្តី ក៏នៅមានបញ្ហាសិទ្ធិមនុស្សដទៃផ្សេងទៀតដែលនៅតែជាកង្វល់សម្រាប់អ្នករាយការណ៍ពិសេស។

៦. ឧទាហរណ៍ សិទ្ធិលើដីធ្លីនៅតែជាបញ្ហាដ៏ធំមួយនៅក្នុងប្រទេសនេះ។ បញ្ហាដែលជាកង្វល់មួយទៀតគឺសេរីភាពក្នុងការបញ្ចេញមតិ ដែលនៅតែមានភាពទន់ខ្សោយ និងស្ថិតក្នុងការរិះគន់ នៅក្នុងអំឡុងពេលនៃការពិនិត្យ។ និទណ្ឌភាពគឺជាបញ្ហារ៉ាំរ៉ៃមួយ។ ឯករាជ្យភាពនៃស្ថាប័នតុលាការ និងសមត្ថភាពរបស់សភាក្នុងការបំពេញមុខងារជាអ្នកត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើការងាររបស់អង្គនីតិប្រតិបត្តិ ក៏នៅ

តែជាបញ្ហាដែរ។ ស្ថិតនៅក្នុងបរិបទនេះ នៅក្នុងដំណើរបេសកកម្មទាំងពីររបស់លោកនៅក្នុងអំឡុងពេលនៃការពិនិត្យ អ្នករាយការណ៍ពិសេសបានសម្រេចជ្រើសយកការយកចិត្តទុកដាក់លើការឃ្លាំមើលការអនុវត្តអនុសាសន៍របស់លោក។

## II. លិខិតដែលបានផ្ញើជូនរដ្ឋាភិបាល

៧. នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ អ្នករាយការណ៍ពិសេសបានផ្ញើលិខិតមួយចំនួន ទៅរដ្ឋាភិបាលអំពីករណីជាក់លាក់ដែលជាកង្វល់ខាងសិទ្ធិមនុស្ស ដូចរៀបរាប់ខាងក្រោមនេះ។

៨. លិខិតអំពាវនាវបន្ទាន់រួមគ្នាត្រូវបានផ្ញើនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១២ ទាក់ទងនឹងគ្រួសារប្រជាពលរដ្ឋរស់នៅលើដីមានទំនាស់ក្នុងតំបន់បឹងកក់។ លិខិតនេះត្រូវបានធ្វើឡើងរួមគ្នាដោយប្រធានអ្នករាយការណ៍នៃក្រុមការងារទទួលបន្ទុកការឃុំខ្លួនដោយបំពាន អ្នករាយការណ៍ពិសេសទទួលបន្ទុកការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការសំដែងមតិ និងយោបល់  អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមានលំនៅដ្ឋានសមរម្យដែលជាផ្នែកមួយនៃសិទ្ធិមានកម្រិតជីវភាពរស់នៅសមរម្យ និងសិទ្ធិមិនមានការរើសអើងនៅក្នុងបរិបទនេះ អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិភាព និងសិទ្ធិបង្កើតសមាគម អ្នករាយការណ៍ពិសេសទទួលបន្ទុកសេរីភាពខាងសាសនា ឬ ជំនឿ អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស អ្នករាយការណ៍ពិសេសទទួលបន្ទុកឯករាជ្យភាពរបស់ចៅក្រម និងមេធាវី និងអ្នករាយការណ៍ពិសេសទទួលបន្ទុកអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ ព្រមទាំងហេតុ និងផលនៃអំពើហិង្សា។ លិខិតអំពាវនាវបន្ទាន់រួមគ្នានេះបានទាក់ទាញការយកចិត្តទុកដាក់ទៅលើព័ត៌មានទាក់ទងនឹងការចាប់ខ្លួន និងការកាត់ទោសស្ត្រី ១៣ នាក់មកពីសហាគមន៍បឹងកក់ នៅក្នុងអំឡុងពេលតវ៉ាដោយសន្តិវិធីរបស់ពួកគេ រួមទាំងការចាប់ខ្លួនតំណាងពីរនាក់ផ្សេងទៀតពីតំបន់នោះ ព្រមទាំងការចាប់ខ្លួនព្រះតេជគុណ លួន សាវ៉ាត និងការប្រើឥទ្ធិពលមិនសមស្របទៅលើព្រះអង្គឲ្យឈប់ធ្វើការងារសិទ្ធិមនុស្ស។ មានការសំដែងក្តីកង្វល់ថា សិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិភាពរបស់អ្នកតំណាងសហគមន៍បឹងកក់ចំនួន ១៥ នាក់  និងព្រះតេជគុណ លួន សាវ៉ាត អាចត្រូវបានគេរំលោភបំពាន ហើយការរំលោភបំពានទាំងនេះអាចទាក់ទងដោយផ្ទាល់ទៅនឹងសកម្មភាពរបស់ពួកគេក្នុងការការពារសិទ្ធិមនុស្ស។

៩. នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២ លិខិតការចោទប្រកាន់រួមគ្នាមួយត្រូវបានបញ្ជូនរួមគ្នាដោយអ្នករាយការណ៍ពិសេសទទួលបន្ទុកការលើកំពស់ និងការការពារសិទ្ធិសេរីភាពក្នុងការសំដែងមតិនិងយោបល់ អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិភាព និងសិទ្ធិបង្កើតសមាគម និងអ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស។ លិខិតនោះបានលើកឡើងពីស្ថានភាពនៃបុគ្គលិកពីរនាក់របស់អង្គការសិទ្ធិមនុស្សមិនមែនរដ្ឋាភិបាល មាន លោក ប៉ែន បុណ្ណា បុគ្គលិកសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា (អាដហុក) និងលោក ជឹម សាវុធ បុគ្គលិកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាម).ស.ម.ក)។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា រួមជាមួយនឹងអង្គការសិទ្ធិមនុស្សមិនមែនរដ្ឋាភិបាលផ្សេងទៀត គឺជាកម្មវត្ថុនៃលិខិតមួយដែលបានផ្ញើនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១១ ទាក់ទងនឹងហេតុការណ៍ ដែលបានកើតឡើងនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២។ លោក ប៉ែន បុណ្ណា និងលោក ជឹម សាវុធ

បានធ្វើការបណ្ដឹះបណ្ដាលអំពីសិទ្ធិមានដីធ្លីក្នុងភូមិប៉ាតាង។ ទោះបីជាបានធ្វើលិខិតមួយច្បាប់ផ្ញើទៅប្រធានភូមិប៉ាតាងជម្រាបជូនគាត់ឲ្យបានដឹងអំពីវគ្គបណ្ដុះបណ្ដាលនេះហើយក៏ដោយ ក៏ការវគ្គបណ្ដុះបណ្ដាលត្រូវបានរំខានដោយមន្ត្រីអនុវត្តច្បាប់ដែរ។ មន្ត្រីអនុវត្តច្បាប់ថែមទាំងបានធ្វើការចោទប្រកាន់សមាគមអាដហុកពីបទធ្វើសកម្មភាព" ញុះញង់" និងបានព្រមានអ្នកទាំងពីរឲ្យចាកចេញពីតំបន់នោះ បើពុំនោះទេ សន្តិសុខរបស់ពួកគេនឹងមិនត្រូវបានធានាឡើយ។ មានការសំដែងកង្វល់ថា ការរំខានដល់វគ្គបណ្ដុះបណ្ដាលសិទ្ធិមនុស្សនិងការគំរាមកំហែងលើបុគ្គលិកទាំងពីរនាក់នេះ អាចពាក់ព័ន្ធនឹងការប្រើប្រាស់សិទ្ធិសេរីភាពរបស់គេក្នុងការជួបប្រជុំដោយសន្តិវិធី សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម។

១០. លិខិតអំពាវនាវបន្ទាន់រួមគ្នាមួយទៀត ត្រូវបានផ្ញើរួមគ្នានៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២ ដោយប្រធានអ្នករាយការណ៍នៃក្រុមការងារទទួលបន្ទុកការឃុំខ្លួនដោយបំពាន អ្នករាយការណ៍ពិសេសទទួលបន្ទុកការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការសំដែងមតិ និងយោបល់ អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិភាព និងសិទ្ធិបង្កើតសមាគម និងអ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្ស។ លិខិតនេះបានលើកឡើងអំពីការចោទប្រកាន់ទៅលើលោក ម៉ម សូណង់ដូ ជាប្រធាន និងជាម្ចាស់ស្ថានីយ៍វិទ្យុឯករាជ្យ FM 105 (វិទ្យុសំបុកឃ្មុំ(។ លោក ម៉ម សូណង់ដូ ជាកម្មវត្ថុនៃលិខិតមួយចំនួនដែលបានដាក់ជូនរដ្ឋាភិបាលកម្ពុជា ក្នុងនាមនីតិវិធីពិសេស រាប់ទាំងលិខិតអំពាវនាវបន្ទាន់មួយ ដែលបានផ្ញើនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៥ និងលិខិតចោទ ប្រកាន់មួយដែលបានផ្ញើនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៦។ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២ លោក ម៉ម សូណង់ដូ (ប្រធានអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលបានបង្កើតឡើងដើម្បីលើកស្ទួយសេរីភាព ប្រជាធិបតេយ្យ និងលើកស្ទួយការយល់ដឹងអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ( ត្រូវបានតុលាការរាជធានីភ្នំពេញចោទប្រកាន់ជាផ្លូវការផ្អែកតាមមាត្រាចំនួនប្រាំមួយនៃក្រមព្រហ្មទណ្ឌ ដែលរួមមាន "កុប្បកម្ម" និង "ញុះញង់ឲ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនឹង អាជ្ញាធរស្របច្បាប់"។ របាយការណ៍បានលើកឡើងថា ការចោទប្រកាន់លោក ម៉ម សូណង់ដូ អាចកើតចេញពីសុន្ទរកថា ដែលបានថ្លែងដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលក្នុងនោះលោក ម៉ម សូណង់ដូ ត្រូវបានចោទប្រកាន់ពីបទ ផ្ដើមគំនិតក្នុងការរៀបចំផែនការឲ្យប្រជាពលរដ្ឋក្នុងភូមិមួយនៅខេត្តក្រចេះបំបែកខ្លួនចេញពីប្រទេសកម្ពុជា និងបង្កើតជារដ្ឋឯករាជ្យ។ សេចក្ដីថ្លែងការណ៍របស់លោកនាយករដ្ឋ មន្ត្រីធ្វើឡើងមួយថ្ងៃបន្ទាប់ពីវិទ្យុសំបុកឃ្មុំចាក់ផ្សាយរបាយការណ៍ស្ដីពីបណ្ដឹងមួយដែលបានដាក់ទៅតុលាការព្រហ្មទណ្ឌអន្តរជាតិនៅថ្ងៃទី២២ ខែមិថុនា ដោយចោទប្រកាន់រដ្ឋាភិបាលថាបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយការបណ្ដេញប្រជាពលរដ្ឋរាប់ពាន់នាក់ដោយបង្ខំចេញពីដីធ្លី និងលំនៅដ្ឋានរបស់ខ្លួន។ មានការសំដែងកង្វល់ថា ការចាប់ខ្លួន ការឃុំខ្លួន និងការកាត់ទោសលោក ម៉ម សូណង់ដូ អាចជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការងារស្របច្បាប់របស់គាត់ ក្នុងការលើកកំពស់ការយល់ដឹងអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅប្រទេសកម្ពុជា។ មានកង្វល់ទៀតថា ការចោទប្រកាន់លើរូបគាត់ អាចបង្ហាញពីការប៉ុនប៉ងដោយផ្ទាល់ក្នុងការរារាំងគាត់មិនឲ្យប្រើប្រាស់សិទ្ធិស្របច្បាប់ខាងសេរីភាពក្នុងការសំដែងមតិ។

១១. ម្យ៉ាងវិញទៀត លិខិតចោទប្រកាន់រួមគ្នាមួយដែលបានផ្ញើនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២ បានលើកឡើងអំពីការកាត់ទោសលោក ម៉ម សូណង់ដូ ហើយត្រូវផ្ញើរួមគ្នាដោយអ្នករាយការណ៍ពិសេស

ទទួលបន្ទុកការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការសំដែងមតិនិងយោបល់ អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមនុស្ស គ្រប់រូបក្នុងការទទួលបានកម្រិតបទដ្ឋានខ្ពស់បំផុតផ្នែកសុខភាពផ្លូវកាយ និងផ្លូវចិត្ត អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពរបស់ អ្នកការពារសិទ្ធិមនុស្ស និងអ្នករាយការណ៍ពិសេសទទួលបន្ទុកឯករាជ្យភាពរបស់ចៅក្រម និងមេធាវី។ នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១២ លោក ម៉ម សូណង់ដូ ត្រូវបានរកឃើញថាមានពិរុទ្ធជាអ្នកផ្តើមគំនិតបង្កើតឲ្យមានកុប្បកម្ម ញុះញង់ឱ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនឹងអាជ្ញាធរស្របច្បាប់ ស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ និងជ្រៀតជ្រែកដោយខុសច្បាប់ទៅក្នុងការបំពេញមុខងារសាធារណៈ។ លោក ម៉ម សូណង់ដូ ត្រូវបានគេរាយការណ៍ថា បានឆ្លងជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរនៅក្នុងពន្ធនាគារ និងត្រូវការការព្យាបាលជំងឺជាចាំបាច់។ មានការសំដែងកង្វល់ខ្លាំងថា ការកាត់ទោសលោក ម៉ម សូណង់ដូ ឲ្យជាប់ពន្ធនាគាររយៈពេលវែង អាចបានបង្ហាញពីការប៉ុនប៉ងដោយផ្ទាល់ ដើម្បីរារាំង គាត់មិនឲ្យប្រើប្រាស់សិទ្ធិសេរីភាពក្នុងការសំដែងមតិស្របច្បាប់របស់គាត់។ លើសពីនេះទៅទៀត មានការសំដែងកង្វល់ តាមរយៈការចោទប្រកាន់ដែលទទួលបានបង្ហាញថា ស្ថានភាពរបស់លោក ម៉ម សូណង់ដូ អាចត្រូវបានភ្ជាប់ទៅនឹងសកម្មភាពរបស់គាត់នៅក្នុងការលើកស្ទួយសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។

១២. នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៣ តាមរយៈសេចក្តីប្រកាសព័ត៌មាន អ្នករាយការណ៍ពិសេសបានស្វាគមន៍ចំពោះការដោះលែងលោក ម៉ម សូណង់ដូ បន្ទាប់ពីសាលាឧទ្ធរណ៍ក្នុងប្រទេសកម្ពុជាបានចេញសេចក្តីសម្រេចមួយ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣។ លោកបានកត់សំគាល់ថា សាលាឧទ្ធរណ៍បានរកឃើញថា ពុំមានភស្តុតាងគាំទ្រការចោទប្រកាន់ភាគច្រើន បន្ទាប់ពីសាលាដំបូងបានកាត់ទោសគាត់ឲ្យជាប់ពន្ធនាគាររយៈពេលរហូតដល់ទៅ ២០ ឆ្នាំពីបទចោទជាច្រើន ក្នុងនោះរួមមានបទផ្តើមគំនិតឲ្យមានកុប្បកម្មផងដែរ។ លោកក៏បានកត់សំគាល់ផងដែរថា កំហុសធំៗនៅក្នុងការជំនុំជម្រះក្តីខាងដើម ដែលត្រូវបានគូសបញ្ជាក់ដោយដៃគូពិភាក្សាមួយចំនួន ដែលអ្នករាយការណ៍ពិសេសបានជួបប្រជុំនៅក្នុងអំឡុងពេលបំពេញបេសកកម្មរបស់លោក មកកាន់ព្រះរាជាណាចក្រកម្ពុជា ក្នុងខែធ្នូ ឆ្នាំ២០១២ ត្រូវបានដោះស្រាយនៅសាលាឧទ្ធរណ៍។ ទោះជាយ៉ាងណាក៏ដោយ លោកមានការសោកស្តាយ ដោយសារទោសមួយចំនួននៅតែមានហើយបទចោទ និងការកាត់ទោសថ្មី ត្រូវបានបញ្ចូល ដោយមិនទុកឱកាសឲ្យជនជាប់ចោទរៀបចំសម្រាប់ការពារខ្លួនឡើយ។

១៣. បន្ថែមពីនេះ នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៣ អ្នករាយការណ៍ពិសេសបានអំពាវនាវឲ្យរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ផ្តល់ទិន្នន័យបំបែកលំអិតតាមខេត្តនីមួយៗ ស្តីពីការអនុវត្តបទបញ្ជាលេខ០១ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការ ដើម្បីពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច (រាប់ទាំងចំនួនដី គិតជាហិកតា ដែលបានចែកជូនក្នុងគោលបំណងផ្តល់ប័ណ្ណកម្មសិទ្ធិឯកជន និងទីតាំងដីដែលបានចេញប័ណ្ណកម្មសិទ្ធិ ព្រមទាំងក្រុមហ៊ុនឯកជនដែលពាក់ព័ន្ធ។( លោកបានកត់សំគាល់ដោយកោតសរសើរអំពីព័ត៌មានបច្ចុប្បន្នភាព នៅលើគេហទំព័រ តាមខេត្តនីមួយៗ និងបានអំពាវនាវឱ្យបញ្ចូលព័ត៌មានច្រើនថែមទៀត ទាក់ទងនឹងសម្បទានដីដែលជាកម្មវត្ថុនៃការកាត់ចេញ និងមុខងាររបស់សម្បទានិក។ ចំពោះបញ្ហានេះ អ្នករាយការណ៍ពិសេសទន្ទឹងរង់ចាំដោយរីករាយថានឹងបានជួបពិភាក្សាបន្ថែម

ទៀត អំពីវិធីសាស្ត្រដែលក្រសួងនេះដោះស្រាយបញ្ហាការផ្តល់ប័ណ្ណកម្មសិទ្ធិលើតំបន់ដីមានទំនាស់រួមទាំងការដោះស្រាយញត្តិរបស់អ្នកភូមិ ដែលបានតវ៉ាប្រឆាំងនឹងការដកពួកគេចេញពីកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ឬការជំទាស់ទៅនឹងដំណើរការវាស់វែងនៅក្នុងអំឡុងពេល ៣០ ថ្ងៃ ចាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ។ ការទប់ស្កាត់ ការទន្ទ្រានយកដីធ្លី និងការធានាសិទ្ធិទទួលបានដំណោះស្រាយសមស្រប នៅតែជាក្តីកង្វល់យ៉ាងខ្លាំងដដែលសម្រាប់អ្នករាយការណ៍ពិសេស។

### III. ការតាមដានការអនុវត្តអនុសាសន៍ស្តីពីប្រព័ន្ធតុលាការ

១៤. របាយការណ៍របស់អ្នករាយការណ៍ពិសេស ដែលបានដាក់ជូនសម័យប្រជុំលើកទីដប់ប្រាំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក្នុងឆ្នាំ២០១០ បានផ្តោតសំខាន់លើប្រព័ន្ធតុលាការ)A/HRC/15/46)។ បីឆ្នាំមកហើយ អ្នករាយការណ៍ពិសេស បានស្វែងរកដើម្បីវាយតម្លៃពីស្ថានភាពនៃការអនុវត្តអនុសាសន៍ទាំងឡាយដែលមាននៅក្នុងរបាយការណ៍នោះ។

១៥. ពាក់ព័ន្ធនឹងកំណែទម្រង់ច្បាប់ អ្នករាយការណ៍ពិសេសមានសេចក្តីរីករាយដោយកត់សំគាល់ឃើញថា បច្ចុប្បន្ននេះ ក្រមធំៗចំនួនបួន ត្រូវបានអនុម័ត និងដាក់ឲ្យអនុវត្តរួចហើយ ក្នុងនោះមានក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី។ ទោះជាយ៉ាងណាក៏ដាយ ច្បាប់សំខាន់ៗមួយចំនួនផ្សេងទៀត នៅតែរង់ចាំអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ជាពិសេស ច្បាប់គ្រឹះចំនួនបី មានច្បាប់លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងច្បាប់ស្តីពីកំណែទម្រង់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម)SCM) នៅតែមិនទាន់ត្រូវបានអនុម័តនៅឡើយ។ ទោះជាយ៉ាងណាក៏ដោយ លោកត្រូវបានលើកទឹកចិត្ត ដោយមានការអះអាងប្រាប់គាត់ថា សេចក្តីព្រាងច្បាប់គ្រឹះទាំងបីនេះ ដែលជាផ្នែកមួយនៃអនុសាសន៍គន្លឹះរបស់លោក ស្ទើរតែត្រូវបានរៀបចំរួចស្រេចហើយ ហើយនឹងត្រូវដាក់ឲ្យដេញដោលគ្នាក្នុងសភានៅក្នុងឆមាសទីមួយក្នុងឆ្នាំ២០១៤។

១៦. ជារួមមក ស្ថានភាពប្រព័ន្ធតុលាការនៅប្រទេសកម្ពុជា មិនបានផ្លាស់ប្តូរជាដំកំភួននៅឡើយ ចាប់តាំងពីឆ្នាំ២០១០ មក។ បើទោះបីជាមានការរីកចម្រើនខ្លះក្តី សន្ទុះនៃកំណែទម្រង់ប្រព័ន្ធតុលាការនៅមានការយឺតយ៉ាវខ្លាំង។ បញ្ហាប្រឈមនេះនៅមានដដែល គឺកង្វះឯករាជ្យភាព បញ្ហាសមត្ថភាព ការខ្វះខាតធនធាន អំពើពុករលួយដ៏រីករាលដាល ដែលធ្វើឲ្យសាធារណជនទូទៅបាត់បង់ទំនុកចិត្តលើសមត្ថភាពនៃប្រព័ន្ធតុលាការក្នុងការផ្តល់ដំណោះស្រាយប្រកបដោយប្រសិទ្ធភាព នៅពេលមានការរំលោភសិទ្ធិមនុស្សកើតឡើង។

១៧. ក្នុងអំឡុងពេលនៃដំណើរបេសកកម្មរបស់លោក ក្នុងខែឧសភា ឆ្នាំ២០១៣ អ្នករាយការណ៍ពិសេស បានជួបជាមួយតំណាងក្រសួងយុត្តិធម៌ តំណាងគណៈមេធាវី និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលធ្វើការក្នុងវិស័យច្បាប់ និងតុលាការ។ បើទោះជាមានការព្យាយាមជាច្រើនលើកច្រើនសារយ៉ាងណាក្តី លោកមានការសោកស្តាយដែលលោកមិនអាចជួបជាមួយចៅក្រម ឬព្រះរាជអាជ្ញា ក្នុងអំឡុងពេលនៃដំណើរបេសកកម្មរបស់លោក។

១៨. ដើម្បីការពារឯករាជ្យភាពរបស់ចៅក្រម និងព្រះរាជអាជ្ញា ជាការចាំបាច់ដែលប្រទេសកម្ពុជាត្រូវអនុម័តច្បាប់គ្រឹះទាំងបីនេះ មានច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងច្បាប់ស្តីពី កំណែទម្រង់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម)SCM)។ អ្នករាយការណ៍ពិសេស លើកទឹកចិត្តរដ្ឋាភិបាលឲ្យចូលរួមពិគ្រោះ យោបល់យ៉ាងពេញលេញ និងប្រកបដោយអត្ថន័យ ជាមួយភាគីពាក់ព័ន្ធទាំងអស់ មុននឹងអនុម័តច្បាប់ទាំងបីនេះ ហើយទន្ទឹងរង់ចាំមើលការអនុម័តច្បាប់ទាំងនេះនៅឆ្នាំក្រោយ។

១៩. ទន្ទឹមនេះ អ្នករាយការណ៍ពិសេស កត់សំគាល់ដោយកង្វល់ថា តាមព័ត៌មានដែលទទួលបាន ចៅក្រម និងព្រះរាជអាជ្ញាមួយចំនួននៅតែបន្តចូលរួមយ៉ាងសកម្មក្នុងសកម្មភាពនយោបាយ។ អ្នករាយការណ៍ពិសេសបញ្ជាក់ជាថ្មីនូវអនុសាសន៍ពីមុនរបស់លោកថា សេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាបច្ចុប្បន្ន ហាមមិនឲ្យសមាជិកសកម្មរបស់គណបក្សនយោបាយកាន់មុខតំណែងក្នុងស្ថាប័នតុលាការ ហើយហាមប្រាមមិនឲ្យចៅក្រម និងព្រះរាជអាជ្ញាធ្វើជាទីប្រឹក្សាឲ្យមេដឹកនាំគណបក្សនយោបាយ ឬរដ្ឋមន្ត្រីផ្សេងៗឡើយ។

២០. ប្រាក់បៀវត្សគ្រប់គ្រាន់របស់ចៅក្រម និងព្រះរាជអាជ្ញា នៅតែជាបញ្ហាសំខាន់ក្នុងការធានាឯករាជ្យភាពរបស់ពួកគេ។ អ្នករាយការណ៍ពិសេសកត់សំគាល់ថា ប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់ឧបត្ថម្ភរបស់ចៅក្រម និងព្រះរាជអាជ្ញាមិនត្រូវបានកើនឡើងទេ ចាប់តាំងពីរបាយការណ៍ចុងក្រោយរបស់លោកស្តីពីប្រព័ន្ធតុលាការ។ ម្យ៉ាងវិញទៀត ថវិកាទូទៅរបស់ប្រព័ន្ធយុត្តិធម៌ មិនបានកើនឡើងជាដុំកំភួនទេ។ តាមតួលេខដែលមានបញ្ជាក់ក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ ក្រសួងយុត្តិធម៌ វិស័យយុត្តិធម៌ទទួលបាន ៩ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១១ជាចំនួនបន្តិចបន្តួចដែលស្មើនឹង០,៣៦%នៃថវិកាជាតិ។

២១. អ្នករាយការណ៍ពិសេសមានបំណងរំលឹកឡើងវិញថា ឯករាជ្យភាពរបស់ព្រះរាជអាជ្ញា គឺមានសារៈសំខាន់ដូច គ្នានឹងឯករាជ្យភាពរបស់ចៅក្រមដែរ ក្នុងការធានាបាននូវសុចរិតភាពនៃប្រព័ន្ធយុត្តិធម៌។ ពាក់ព័ន្ធនឹងលក្ខន្តិកៈរបស់ព្រះរាជអាជ្ញា វានៅតែមិនទាន់ច្បាស់លាស់ថា តើព្រះរាជអាជ្ញានឹងត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌ ឬឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែរឬយ៉ាងណា នៅពេលដែលច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញាថ្មីត្រូវបានអនុម័ត។

២២. អ្នករាយការណ៍ពិសេស ត្រូវបានលើកទឹកចិត្តដោយការវិវឌ្ឍជាវិជ្ជមានមួយចំនួន នៅក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ។ លោកត្រូវបានគេប្រាប់ឲ្យដឹងថា បន្ទាប់ពីមានកិច្ចប្រជុំរវាងម្ចាស់ជំនួយ ដែលបានរៀបចំឡើងដោយការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស)OHCHR) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី(AusAID) បានយល់ព្រមផ្តល់មូលនិធិ ដើម្បីកសាងអគារបន្ថែមសំរាប់សាលាឧទ្ធរណ៍។ ការសាងសង់អគារនេះ ត្រូវបានបញ្ចប់ហើយ ហើយអគារថ្មីនេះ ត្រូវបានសម្ពោធក្នុងឆ្នាំ២០១២។ បច្ចុប្បន្ននេះ មានបន្ទប់សវនាការពីរបន្ថែមទៀត ដែលអាចបើកសវនាការជំនុំ ជម្រះរឿងក្តីបានច្រើនថែមទៀត និងបានធ្វើឱ្យប្រសើរឡើងនូវគ្រឿងបរិក្ខារសម្រាប់ក្រឡាបញ្ជី។ ចៅក្រមសាលាឧទ្ធរណ៍មានចំនួនកើនឡើងផងដែរ។ បច្ចុប្បន្ននេះ រឿងក្តីបណ្តឹងឧទ្ធរណ៍ត្រូវបានបើកសវនាការជំនុំជម្រះក្នុងអំឡុងពេលមួយឆ្នាំ ឬពីរឆ្នាំ ដែលមានការរីកចម្រើនខ្លាំង បើប្រៀបធៀបនឹងស្ថានភាពពីមុនៗ។ ប្រធានសាលាឧទ្ធរណ៍ និងការិយាល័យឧត្តមស្នង

ការទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR)បានធ្វើការជាមួយគ្នាកាលពីឆ្នាំមុន ដើម្បីកាត់បន្ថយសំណុំរឿងកកស្ទះនៅសាលាឧទ្ធរណ៍ ដោយគេរំពឹងថា សំណុំរឿងកកស្ទះយូរជាងគេបំផុត)ដែលបានរង់ចាំរយៈពេលជាង ៧ ឆ្នាំហើយនោះ( នឹងត្រូវបានជម្រះនៅត្រឹមបំណាច់ឆ្នាំ២០១៣ នេះ។ ប្រទេសអូស្ត្រាលី បានផ្តល់មូលនិធិសម្រាប់ប្រព័ន្ធកំព្យូទ័រថ្មីសម្រាប់ការចុះបញ្ជី និងការគ្រប់គ្រងសំណុំរឿង។ ជារួមមក ការគ្រប់គ្រងតុលាការនៅសាលាឧទ្ធរណ៍បានល្អប្រសើរហើយ។ តាមព័ត៌មានដែលទទួលបាន សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការចែងពីការបង្កើតសាលាឧទ្ធរណ៍ថ្មីនៅតាមបណ្តាខេត្ត ដែលសង្ឃឹមថានឹងធ្វើឲ្យដំណើរការដោះស្រាយបណ្តឹងឧទ្ធរណ៍បានប្រសើរឡើងថែមទៀត។

២៣. អ្នករាយការណ៍ពិសេស មានទឹកចិត្តរីករាយដោយដឹងថា គណៈមេធាវីបានធ្វើវិសោធនកម្មក្រមសីលធម៌វិជ្ជាជីវៈមេធាវីរបស់ខ្លួន ដោយមានជំនួយបច្ចេកទេសពីការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR)។ ក្រមសីលធម៌វិជ្ជាជីវៈថ្មីនេះ ត្រូវបានអនុម័ត ក្នុងខែកញ្ញា ឆ្នាំ២០១២។ ក្រមសីលធម៌នេះតម្រូវឲ្យមេធាវីគោរព និងលើកស្ទួយសិទ្ធិមនុស្ស។ ក្រមសីលធម៌ថ្មីនេះ ក៏ចែងផងដែរថា មេធាវីមិនចាំបាច់ពិគ្រោះយោបល់ ឬជូនដំណឹងទៅប្រធានគណៈមេធាវីទេ នៅពេលដែលពួកគេមានបំណងនិយាយទៅកាន់ប្រព័ន្ធផ្សព្វផ្សាយ ដែលករណីនេះមាននៅក្នុងក្រមសីលធម៌វិជ្ជាជីវៈចាស់។ កាលពីដើមឆ្នាំនេះ ប្រធានគណៈមេធាវីថ្មី បានបង្កភាពចម្រូងចម្រាសដោយព្រមានមេធាវីឲ្យប្រុងប្រយ័ត្នមុននឹងចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់តាមវិទ្យុ ឬទូរទស្សន៍។ ករណីនេះ ត្រូវបានគេបកស្រាយថាជាការព្យាយាមបិទបាំង ដើម្បីហាមឃាត់មិនឲ្យមេធាវីនិយាយទៅកាន់ប្រព័ន្ធផ្សព្វផ្សាយ។ អ្នករាយការណ៍ពិសេស មានសេចក្តីរីករាយ ដោយបានឮតំណាងមួយរូបរបស់ប្រធានគណៈមេធាវី ដែលបានអះអាងថា មេធាវីមានសិទ្ធិនិយាយស្តីដោយសេរីទៅកាន់ប្រព័ន្ធផ្សព្វផ្សាយ។

២៤. ចំនួនមេធាវីនៅមានកម្រិតទាបខ្លាំងនៅឡើយនៅប្រទេសកម្ពុជា បើប្រៀបធៀបទៅនឹងបណ្តាប្រទេសដទៃច្រើនទៀត។ ចំនួនមេធាវីការពារជនក្រីក្រ ពិតជាមានចំនួនមិនគ្រប់គ្រាន់ទេ ហើយមេធាវីទាំងនោះ ភាគច្រើនធ្វើការនៅរាជធានីភ្នំពេញ។ តាមក្រមនីតិវិធីព្រហ្មទណ្ឌ ជនដែលត្រូវបានចាប់ខ្លួន មានសិទ្ធិទាក់ទងមេធាវីបាន តែក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតប៉ុណ្ណោះ។ បើទោះជាដូច្នេះក្តី តាមការជាក់ស្តែង ជនត្រូវបានចាប់ខ្លួនមានចំនួនតិចតួចបំផុត  ទទួលបានសិទ្ធិទាក់ទងជាមួយមេធាវី ដែលការនេះអាចមកពីនគរបាលយុត្តិធម៌បន្តបដិសេធសិទ្ធិទាំងនេះ ឬអាចមកពីរកមេធាវីមិនបាន។ អាស្រ័យហេតុនេះ អ្នករាយការណ៍ពិសេសចង់បញ្ជាក់ឡើងវិញនូវអនុសាសន៍មុនៗរបស់លោក ដែលស្នើឲ្យរដ្ឋាភិបាលពិនិត្យពិចារណាលើការធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ដោយចែងពីសិទ្ធិទទួលបានមេធាវីភ្លាមៗ នៅក្នុងអំឡុងពេលឃាត់ខ្លួន ស្របតាមការអនុវត្តល្អជាអន្តរជាតិ។

២៥. ជំនួយផ្នែកច្បាប់សំរាប់ជនក្រីក្រ ភាគច្រើនត្រូវបានផ្តល់តាមរយៈអង្គការមិនមែនរដ្ឋាភិបាលដែលបានគាំទ្រដោយម្ចាស់ជំនួយអន្តរជាតិ។ ទោះជាយ៉ាងណា ការផ្តល់មូលនិធិត្រូវបានកាត់បន្ថយយ៉ាងខ្លាំងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ លើសពីនេះទៀត ការផ្តល់មូលនិធិពីម្ចាស់ជំនួយភាគច្រើនបំផុតត្រូវបានកំណត់ជាក់លាក់សម្រាប់ប្រភេទរឿងក្តីមួយចំនួន ដូចជារឿងក្តីជួញដូរមនុស្ស រឿងក្តីអំពើហិង្សាក្នុងគ្រួសាររឿងក្តីអនីតិជន។ល។ មូលនិធិតិចតួច ដែលអាចរកបានសម្រាប់កិច្ចការជំនួយផ្នែកច្បាប់សម្រាប់

ជនក្រីក្រទូទៅ។ នៅខេត្តមួយចំនួននៃប្រទេសកម្ពុជា មិនមានមេធាវីការពារជនក្រីក្រសូម្បីតែម្នាក់ឡើយ ដែលការនេះជាបញ្ហាធ្ងន់ធ្ងរចំពោះសិទ្ធិទទួលបានយុត្តិធម៌។ តាមក្រមនីតិវិធីព្រហ្មទណ្ឌ ជំនួយពីមេធាវីត្រូវតែមានជាដាច់ខាតសំរាប់ករណីបទឧក្រិដ្ឋ និងករណីអនីតិជន ដែលមានន័យថា ប្រសិនជាមិនមានមេធាវីការពារទេនោះ រឿងក្តីនេះមិនអាចបន្តនីតិវិធីបានទេ។

២៦. ដើម្បីធានាសិទ្ធិទទួលបានយុត្តិធម៌សំរាប់ប្រជាពលរដ្ឋក្រីក្របំផុតនោះ រដ្ឋាភិបាលត្រូវធ្វើការពិចារណាជាបន្ទាន់អំពីការបង្កើតឲ្យមានប្រព័ន្ធជំនួយផ្នែកច្បាប់សំរាប់ជនក្រីក្រថ្នាក់ជាតិ ស្របតាមគោលការណ៍ និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ )A/RES/67/187) របស់អង្គការសហប្រជាជាតិ ដែលទើបបានអនុម័តថ្មីៗ។ អ្នករាយការណ៍ពិសេស ចង់រំលឹកឡើងវិញផងដែរថា សិទ្ធិទទួលបានយុត្តិធម៌ អាចត្រូវបានធ្វើឲ្យប្រសើរឡើង តាមរយៈវិធានការនានា ដូចជាការបង្កើនចំនួនមេធាវី និងការប្រើជំនួយការមេធាវីនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងការជំរុញឲ្យរដ្ឋាភិបាលស្វែងរកមធ្យោបាយទាំងនេះ។

២៧. អ្នករាយការណ៍ពិសេសមានកង្វល់ថា ចៅក្រមនៅតែបន្តប្រើបញ្ញត្តិនៃក្រមព្រហ្មទណ្ឌប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស និងអ្នកបញ្ចេញមតិមិនគាំទ្រដល់រដ្ឋាភិបាល។ អ្នករាយការណ៍ពិសេសបានសង្កេតឃើញនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះថា ព្រះរាជអាជ្ញាមានទំនោរទៅរកការបោះបង់ចោលនូវការចោទប្រកាន់បទបរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិត ដោយប្រើបទញុះញង់ជំនួសវិញ )មាត្រា ៤៩៤ ដល់ មាត្រា ៤៩៨ នៃក្រមព្រហ្មទណ្ឌ។( គួរកត់សំគាល់នៅត្រង់នេះថា ការបរិហាកេរ្តិ៍អាចឈានដល់ការពិន័យជាប្រាក់ ចំណែកឯការញុះញង់អាចឈានដល់ការដាក់ទោសពន្ធនាគារ។

២៨. កាលពីឆ្នាំមុន មានរឿងក្តីធំបំផុតមួយបានទាក់ទាញចំណាប់អារម្មណ៍អន្តរជាតិជាខ្លាំងផងដែរ គឺរឿងក្តីលោក ម៉ម សូណង់ដូ ដែលជាម្ចាស់ស្ថានីយ៍វិទ្យុសំបុកឃ្មុំ ដែលគាត់ត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ ២០ ឆ្នាំ ពីការចោទប្រកាន់មិនត្រឹមត្រូវមួយចំនួន ដែលផ្តោតលើការញុះញង់ឲ្យបង្កើតអបគមន៍។ ទោសរបស់គាត់ត្រូវបានកាត់បន្ថយនៅសាលាឧទ្ធរណ៍ ហើយគាត់ត្រូវបានដោះលែង។ យោងទៅតាមព័ត៌មានដែលទទួលបាន វាហាក់ដូចជាថា បុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាលបានរងការគំរាមកំហែងចោទប្រកាន់ពីបទញុះញង់ជាប្រចាំ។

## IV. ការតាមដានការអនុវត្តអនុសាសន៍ស្តីពីសភា

២៩. នៅក្នុងរបាយការណ៍ ឆ្នាំ២០១១ របស់លោកដាក់ជូនសម័យប្រជុំលើកទីដប់ប្រាំបី នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស)A/HRC/18/46) អ្នករាយការណ៍ពិសេស បានរៀបរាប់ជាបន្តបន្ទាប់អំពីវិធានការផ្សេងៗ ដែលលោកចាត់ទុកថាមានសារៈសំខាន់សម្រាប់ប្រទេសកម្ពុជា ដើម្បីពន្លឿនដំណើរការប្រជាធិបតេយ្យនីយកម្មនៅក្នុងប្រទេសនេះ ពាក់ព័ន្ធនឹងការងាររបស់សភា។ អនុសាសន៍ភាគច្រើនពាក់ព័ន្ធនឹងបញ្ហាជាក់លាក់ ដែលប៉ះពាល់ដោយផ្ទាល់ទៅលើសមត្ថភាពរបស់សភា សម្រាប់ការប្រព្រឹត្តទៅយ៉ាងត្រឹមត្រូវ ការអនុម័តច្បាប់ ដែលលើកស្ទួយ និងការពារសិទ្ធិមនុស្ស ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានទទួលបាន និងធ្វើជាគំរូដល់

សង្គម ក្នុងការធ្វើអន្តរគូបនីយកម្មវប្បធម៌រិះគន់ក្នុងន័យស្ថាបនា ការចែករំលែកមតិយោបល់ និងអំណាច ព្រមទាំងឆន្ទៈពិតប្រាកដនៃគោលបំណងរួម។

៣០. ក្នុងចំណោមអនុសាសន៍សំខាន់ៗរបស់លោក រួមមាន ៖

ក. លោកបានស្នើថា នីតិវិធីក្នុងការដកអភ័យឯកសិទ្ធិសភា និងវិធានការដាក់វិន័យដទៃទៀត ទៅលើសមាជិកសភា គួរតែធ្វើឡើងស្របតាមគោលការណ៍យុត្តិធម៌ធម្មជាតិ បទដ្ឋានរដ្ឋធម្មនុញ្ញ និងសេរីភាពក្នុងការបញ្ចេញមតិ។

ខ. រដ្ឋាភិបាលគួរតែបង្កើនធនធានបម្រុងទុកសម្រាប់រដ្ឋសភា ដើម្បីបង្កើនសមត្ថភាពទូទៅរបស់សភាជាស្ថាប័នឯករាជ្យ និងមានប្រសិទ្ធភាព និងសមត្ថភាពរបស់សមាជិកសភាម្នាក់ៗ ដើម្បីពិនិត្យមើលសេចក្តីព្រាងច្បាប់ដែលរដ្ឋាភិបាលបានដាក់ឲ្យជជែកវែកញែកនៅក្នុងសភា។

គ. លោកបានគូសបញ្ជាក់ផងដែរថា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងតម្រូវជាចាំបាច់ឲ្យធ្វើសមាជជាតិម្តងក្នុងមួយឆ្នាំ ក្រោមព្រះរាជអធិបតីភាពនៃព្រះមហាក្សត្រ ដើម្បីឲ្យប្រជាពលរដ្ឋផ្តល់ព័ត៌មានដោយផ្ទាល់លើបញ្ហាផ្សេងៗ ដែលជាប្រយោជន៍ជាតិ និងលើកយកបញ្ហាដែលជាកង្វល់ប្រាប់អាជ្ញាធរនៃស្ថាប័នធំៗទាំងបីរបស់រដ្ឋ។ ដៃគូពិភាក្សាម្នាក់យល់ឃើញថា ទស្សនទាននៃសមាជជាតិនេះ មិនចាំបាច់មានទៀតទេ នៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ដោយសារថា រដ្ឋសភា និងព្រឹទ្ធសភាគឺជាស្ថាប័នដែលដើរតួនាទីតំណាងឲ្យប្រជាពលរដ្ឋរួចហើយ។ ទោះជាយ៉ាងណាក៏ដោយ សមាជជាតិនៅតែតម្រូវឲ្យមានតាមបញ្ញត្តិរដ្ឋធម្មនុញ្ញ។ ដោយសារព្រះមហាក្សត្រទ្រង់ជាអ្នកធានាការពាររដ្ឋធម្មនុញ្ញ ដូច្នេះ ព្រះមហាក្សត្រ គួរតែអាចទទួលជួបសវនាការ និងទទួលព័ត៌មានពីប្រជាពលរដ្ឋគ្រប់ស្រទាប់នៃសង្គម។ សមាជជាតិគួរតែបានធ្វើជារៀងរាល់ឆ្នាំ ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ។ ចំពោះបញ្ហានេះ ច្បាប់រៀបចំអង្គការទាក់ទងនឹងសមាជជាតិ គួរតែត្រូវបានអនុម័តដោយគ្មានការយឺតយ៉ាវ។

ឃ. លោកបានអំពាវនាវឲ្យពង្រឹងតួនាទីរបស់គណៈកម្មការសិទ្ធិមនុស្សនៅក្នុងសភា ដើម្បីបញ្ជៀបសិទ្ធិមនុស្សជាបញ្ហាពហុវិស័យនិងដើម្បីធានាឲ្យច្បាប់ជាតិស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

ង. លោកបានអំពាវនាវដល់សមាជិកសភាគ្រប់រូប រាប់ទាំងសមាជិកគណបក្សប្រឆាំងផងដែរ ឲ្យចូលរួមយ៉ាងពេញលេញក្នុងការងាររបស់សភា និងសហការ ជាពិសេស នៅក្នុងការងាររបស់គណៈកម្មការនៃរដ្ឋសភា។

ឆ. ទាក់ទងនឹងក្រុមប្រឹក្សាធម្មនុញ្ញ លោកបានផ្តល់ជាអនុសាសន៍ថា គួរតែពិនិត្យឡើងវិញ មិនត្រឹមតែច្បាប់អនុម័តដោយសភាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបទបញ្ជាផ្ទៃក្នុងរបស់សភាជាទូទៅ និងរដ្ឋសភាជាពិសេសដើម្បីធ្វើឲ្យប្រាកដថា ច្បាប់ និងបទបញ្ជាផ្ទៃក្នុងទាំងនោះ ពិតជាស្របតាមរដ្ឋធម្មនុញ្ញ

បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងគោលការណ៍នីតិរដ្ឋ រាប់ទាំងគោលការណ៍យុត្តិធម៌ធម្មជាតិផងដែរ។

ជ. ក្នុងចំណោមភារកិច្ចបន្ទាន់ៗនៅចំពោះមុខសភា មានភារកិច្ចមួយគឺពិនិត្យក្រមព្រហ្មទណ្ឌថ្មី សំដៅធានាឲ្យក្រមនេះស្របតាមការកម្រិតដែលអនុញ្ញាតចំពោះសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ តាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ សភាគួរតែការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់សមាជិកខ្លួន និងការពារអភ័យឯកសិទ្ធិសភរបស់ខ្លួន។

៣១. ទាក់ទងនឹងអនុសាសន៍របស់លោកស្តីពីកំណែទម្រង់សភា អ្នករាយការណ៍ពិសេសត្រូវបានលើកទឹកចិត្ត ដោយមានការឆ្លើយតបជាវិជ្ជមានពីប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនា និងព័ត៌មាននៃរដ្ឋសភា និងអគ្គលេខាធិការនៃព្រឹទ្ធសភា និងអំពីឆន្ទៈក្នុងការអនុវត្តអនុសាសន៍ភាគច្រើននៅក្នុងសភាអាណត្តិក្រោយ។ លោកបានផ្តល់ព័ត៌មានអំពីកិច្ចខិតខំប្រឹងប្រែងដែលកំពុងធ្វើ ដើម្បីអនុវត្តអនុសាសន៍មួយចំនួន និងការលំបាកក្នុងការ អនុវត្តអនុសាសន៍ដទៃទៀតរបស់លោក។ ទោះជាយ៉ាងណាក៏ដោយ ទាក់ទងនឹងអនុសាសន៍ស្ទើរតែទាំងអស់របស់លោក លោកមានការសោកស្តាយដោយលើកឡើងថា វឌ្ឍនភាពនៅពេលថ្មីៗនេះមិនបង្ហាញពីភាពជឿនលឿនទៅមុខឆ្ពោះទៅរកការការពារសិទ្ធិមនុស្សឲ្យប្រសើរឡើងថែមទៀតនោះទេ ប៉ុន្តែផ្ទុយមកវិញ វាគឺជាការត្រឡប់ថយក្រោយមួយគួរឲ្យព្រួយបារម្ភទៅវិញ។ ការអនុម័តច្បាប់សំខាន់បំផុតមួយចំនួនដែលបានលើកឡើងក្នុងរបាយណ៍របស់លោកមិនបានមានការរីកចម្រើននោះទេ។ រយៈពេលតែប៉ុន្មានថ្ងៃបន្ទាប់ពីបេសកកម្មរបស់លោក គេឃើញមានការបណ្តេញសមាជិកសភាមកពីគណបក្សប្រឆាំងចំនួន ២៩ រូប នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៣ នៅ មុនថ្ងៃចាប់ផ្តើមរយៈពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោតជាផ្លូវការ។ តាមរយៈសកម្មភាពនេះ សមាជិកសភាទាំងនោះត្រូវបានគេបដិសេធមិនត្រឹមតែលទ្ធភាពក្នុងការធ្វើសាររបស់ខ្លួនតាមរយៈសភាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបដិសេធបៀវត្ស និងអភ័យឯកសិទ្ធិសភារួចផុតពីការចោទប្រកាន់របស់ខ្លួនផងដែរ ដែលសកម្មភាពនេះបានបង្កើតឲ្យមានបរិយាកាសមិនល្អ និងមិនប្រជាធិបតេយ្យ សម្រាប់គោលការណ៍គ្រឹះដ៏សំខាន់មួយនេះ  ក្នុងការអភិវឌ្ឍនយោបាយជាតិ។

៣២. ដោយចងចាំក្នុងចិត្ត អ្នករាយការណ៍ពិសេសអំពាវនាវជាថ្មីម្តងទៀតឲ្យរដ្ឋាភិបាលពិនិត្យមើលឡើងវិញ នូវអនុសាសន៍ទាំងឡាយដែលមាននៅក្នុងរបាយការណ៍របស់លោក ស្តីពីកំណែទម្រង់សភា ក្នុងគោលដៅអនុវត្តអនុសាសន៍ទាំងនោះដោយគ្មានយឺតយ៉ាវទៀតឡើយ ។

## V. ការតាមដានការអនុវត្តអនុសាសន៍ស្តីពីការបោះឆ្នោត

៣៣. ប្រធានបទនៃរបាយការណ៍របស់អ្នករាយការណ៍ពិសេស ដាក់ជូនសម័យប្រជុំលើកទីម្ភៃមួយនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស(A/HRC/21/63) និយាយអំពីកំណែទម្រង់ការបោះឆ្នោត។ នៅក្នុងអំឡុងពេលនៃដំណើរបេសកកម្មរបស់អ្នក រាយការណ៍ពិសេស នៅក្នុងខែឧសភា ឆ្នាំ២០១៣ បានធ្វើឡើងក្នុងពេលវេលាមួយដ៏សំខាន់ដែលប្រទេសនេះ ជិតនឹងរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ របាយការណ៍នេះ ត្រូវ

បានសរសេរបញ្ចប់នៅប៉ុន្មានសប្តាហ៍ មុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដូច្នេះហើយ មិនបានបញ្ចូលនូវស្ថានការណ៍វិវត្តយ៉ាងឆាប់រហ័សក្នុងដំណើរការបោះឆ្នោត ចាប់ពីពេលនោះមកទេ។

៣៤. ប្រជាពលរដ្ឋកម្ពុជានឹងទៅបោះឆ្នោតនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ សំរាប់ការបោះឆ្នោះលើកទីប្រាំបី ចាប់តាំងពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១។[1] គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានប្រកាសថា មានប្រជាជនកម្ពុជាចំនួន ៩.៦៧ លាននាក់ មានសិទ្ធិបោះឆ្នោតក្នុងស្ថានីយបោះឆ្នោតចំនួន ១៩.០០៩ ដើម្បីបោះឆ្នោតអាសនៈសភាចំនួន១២៣ អាសនៈតាមរយៈប្រព័ន្ធបោះឆ្នោតសមាមាត្រ។[2] ការបោះឆ្នោតនេះមានគណ បក្សនយោបាយចំនួន ៨ ចូលរួមប្រកួតប្រជែង។[3] អាសនៈនៅក្នុងរដ្ឋសភាបច្ចុប្បន្ន កាន់កាប់ដោយគណបក្សប្រជាជន កម្ពុជា (៩០ អាសនៈ) គណបក្ស សម រង្ស៊ី (២៦ អាសនៈ) គណបក្សសិទ្ធិមនុស្ស (៣ អាសនៈ) គណបក្សហ៊្វុនស៊ិនប៉ិច (២ អាសនៈ) និងគណបក្សនរោត្តម រណឫទ្ធិ (២ អាសនៈ)។ នៅក្នុងខែកក្កដា ឆ្នាំ២០១២ គណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស បានយល់ព្រមរួមបញ្ចូលគ្នាបង្កើតគណបក្សនយោបាយថ្មីមួយ គឺគណបក្សសង្គ្រោះជាតិ(CNRP)។

៣៥. បើប្រៀបធៀបទៅនឹងការបោះឆ្នោតថ្នាក់ជាតិអាណត្តិមុនៗ ស្ថានភាពទូទៅមុនការបោះឆ្នោតគឺមានសភាពស្ងប់ស្ងាត់ខ្លាំងនៅខណៈពេលកំពុងធ្វើរបាយការណ៍នេះ។ នៅតាមតំបន់ជនបទ ក្រុមការងារផ្នែកសិទ្ធិមនុស្សបានរាយការណ៍ថា មានករណីតិចតួចបំផុតនៃអំពើហិង្សាដោយហេតុផលនយោបាយ ឬការបំភិតបំភ័យលើរាងកាយ។ ការថយចុះស្របគ្នានៅក្នុងកម្រិតនៃអំពើហិង្សាដោយហេតុផលនយោបាយនេះ បង្ហាញឲ្យឃើញពីការរីកចម្រើនដ៏សំខាន់មួយ ឈានទៅរកប្រជាធិបតេយ្យនីយកម្ម។ ទោះជាយ៉ាងណាក៏ដោយ យុទ្ធនាការបំភិតបំភ័យ និងការគៀបសង្កត់នៅតែកើតមានឡើងជាពិសេស នៅតាមតំបន់ជនបទ។ មានសេចក្តីរាយការណ៍ថា ធនធានមនុស្សរបស់រដ្ឋនៅថ្នាក់មូលដ្ឋាន មានដូចជា ប្រធានភូមិ និងមេឃុំ ត្រូវបានគេប្រើប្រាស់ធ្វើជាភ្នាក់ងារនយោបាយ ដើម្បីធ្វើការបញ្ចុះបញ្ចូលប្រជាពលរដ្ឋឲ្យបោះឆ្នោតឲ្យគណបក្សកាន់អំណាចដែលនេះគឺជាការរំលោភយ៉ាងច្បាស់ក្រឡែតទៅនឹងច្បាប់បោះឆ្នោត។ មានសេចក្តីរាយការណ៍ផងដែរថា ស្លាកសញ្ញាគណបក្សនយោបាយរបស់គណបក្សសង្គ្រោះជាតិ(CNRP) ត្រូវបានគេទាញទម្លាក់ ឬបំផ្លិចបំផ្លាញចោលនៅខេត្តស្វាយរៀង ព្រៃវែង តាកែវ កណ្តាល និងខេត្តបាត់ដំបង ដែលជាការរួមចំណែកធ្វើឲ្យមានការភ័យខ្លាចថែមទៀត។ ការជួបជុំគ្នាក្នុងទ្រង់ទ្រាយធំមួយត្រូវបានរៀបចំឡើងដោយគណបក្សប្រឆាំងនៅរាជធានីភ្នំពេញក្នុងខែឧសភា។ អ្នករាយការណ៍ពិសេសមានសេចក្តីរីករាយដោយឃើញថា ការជួបជុំគ្នានេះបានប្រព្រឹត្តទៅដោយសន្តិវិធី ហើយលោកសង្ឃឹមថា វិធីសាស្ត្រសប់ការជួបជុំគ្នាក្នុងទ្រង់ទ្រាយធំបែបនេះ

1 ការបោះឆ្នោតជាតិ ឆ្នាំ១៩៩៣ ដែលស្ថិតក្រោមការត្រួតពិនិត្យរបស់អ៊ុនតាក់ (អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា), ការបោះឆ្នោតជាតិ ឆ្នាំ១៩៩៨, ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០០២, ការបោះឆ្នោតជាតិ ឆ្នាំ២០០៣, ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០០៧, ការបោះឆ្នោតជាតិ ឆ្នាំ២០០៨, ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០១២។

2 រហូតមកដល់ឆ្នាំ២០០៦ ការបង្កើតរដ្ឋាភិបាល តម្រូវឲ្យមានមតិភាគច្រើនពីរភាគបី។ វិសោធនកម្មរដ្ឋធម្មនុញ្ញបច្ចុប្បន្ន អនុញ្ញាតឱ្យមានមតិភាគច្រើនដាច់ខាត ៥០% បូកមួយ ក្នុងរដ្ឋសភា ដើម្បីបង្កើតរដ្ឋាភិបាល។

3 ១គ)គណបក្សសញ្ជាតិកម្ពុជា-.ស.ក( ២គណបក្សហ៊្វុនស៊ិនប៉ិច- (រ.រ.ជ.ក.ឯ.អ.ស.ស( ៣គ )គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ-.ស.រ.ប( ៤ប្រ) គណបក្សប្រជាជនកម្ពុជា-.ជ( ៥- គណបក្សអភិវឌ្ឍន៍សេដ្ឋកិច្ច (K.E.D.P) ៦គណបក្សខ្មែរ- ឈប់ក្រុគ).ខ.ឈ.ក( ៧គ)គណបក្សសង្គ្រោះជាតិ-.ស.ជ៨ និង (-គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យគ).ស.ប(។

ទោះជាក្នុងគោលដៅនៃការបោះឆ្នោត ឬដើម្បីបង្ហាញពីកង្វល់ ឬបញ្ហាពិសេសផ្សេងៗ ដូចជាការទាមទារលក្ខខណ្ឌការងារល្អប្រសើរ ឬការបណ្តេញចេញដោយបង្ខំក៏ដោយក៏ត្រូវតែបានប្រព្រឹត្តទៅ និងដោះស្រាយដោយសន្តិវិធីផងដែរ។

៣៦. ទោះជាយ៉ាងណាក៏ដោយ កង្វល់មួយចំនួនត្រូវបានលើកឡើងទាក់ទងនឹងបរិបទនៃការបោះឆ្នោត ក្នុងនោះកង្វល់ខ្លះលើកឡើងថា ការបោះឆ្នោតមិនមានលក្ខណៈអំណោយផល អាចឲ្យទទួលបានលទ្ធផលដោយសេរី និងយុត្តិធម៌បានឡើយ។ ក្នុងករណីនេះ ទន្ទឹមនឹងអ្នករាយការណ៍ពិសេសយល់ថា គេត្រូវការពេលវេលា ដើម្បីអនុវត្តអនុសាសន៍ មួយចំនួនរបស់លោក និងដើម្បីបង្កើតឆន្ទៈនយោបាយចាំបាច់ ដើម្បីធ្វើកិច្ចការនេះក្តី លោកមានការសោកស្តាយដែលថា អនុសាសន៍ភាគច្រើនរបស់លោក ទាក់ទងនឹងកំណែទម្រង់ការបោះឆ្នោត មិនត្រូវបានអនុវត្តឡើយ។ ជាពិសេស អ្នករាយការណ៍ពិសេសនៅតែមានកង្វល់អំពីឯករាជ្យភាពរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) សេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសម្រាប់គណបក្សនយោបាយទាំងអស់ (ជាពិសេស ទូរទស្សន៍) ការប្រើប្រាស់ធនធានរដ្ឋនៅក្នុងអំឡុងពេលមុនការបោះឆ្នោតដោយគណបក្សនយោបាយ នៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ការប្រើប្រាស់ការគំរាមកំហែងចាត់វិធានការផ្លូវច្បាប់ប្រឆាំងនឹងអ្នកនយោបាយ កង្វល់អំពីសុចរិតភាពនៃបញ្ជីឈ្មោះអ្នកបោះឆ្នោត របាយការណ៍ពីការគំរាមកំហែងដល់អ្នកបោះឆ្នោត និងកង្វះតម្លាភាពជាទូទៅនៅក្នុងដំណើរការបោះឆ្នោត។

៣៧. នៅក្នុងអំឡុងពេលបំពេញបេសកកម្មរបស់លោកនៅក្នុងខែឧសភា អ្នករាយការណ៍ពិសេសបានបញ្ជាក់ឡើងវិញអំពីកង្វល់ទាំងនេះ ក្នុងអំឡុងពេលនៃជំនួបប្រជុំរបស់លោកជាមួយប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងលោកឧបនាយករដ្ឋមន្រ្តី និងជារដ្ឋមន្រ្តីក្រសួងមហាផ្ទៃ។ លោកបានស្វែងរកការធានាពីពួកគាត់ថា នឹងចាត់វិធានការចាំបាច់ ដើម្បីធានាសិទ្ធិប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ដោយគណបក្សនយោបាយទាំងអស់ប្រកបដោយសមធម៌ និងភាពមិនលំអៀងរបស់នគរបាល និងយោធា និងមន្ត្រីរាជការស៊ីវិលនៅក្នុងអំឡុងពេលបោះឆ្នោត។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប)បានផ្តល់ការឆ្លើយតបលំអិតទៅនឹងអនុសាសន៍របស់អ្នករាយការណ៍ពិសេស ដែលមាននៅក្នុងរបាយការណ៍របស់លោកស្តីពីកំណែទម្រង់ការបោះឆ្នោតនិងអំពីកង្វល់ថ្មីៗរបស់សង្គមស៊ីវិលនិងគណបក្សប្រឆាំងក្នុងបញ្ហានេះ។ ទន្ទឹមនឹងអ្នករាយការណ៍ពិសេសមានការពេញចិត្តចំពោះការឆ្លើយតប និងការធានាមួយចំនួន ដែលបានផ្តល់ឲ្យក្តីក៏ការឆ្លើយតបទៅនឹងអនុសាសន៍ភាគច្រើន មិនមានការពេញចិត្តនោះទេ ដូចដែលនឹងពន្យល់ខាងក្រោម។

៣៨. ជាពិសេស អ្នករាយការណ៍ពិសេសមានការសោកស្តាយដែលថា ច្បាប់សំខាន់ដែលគ្រប់គ្រងការបោះឆ្នោត នៅក្នុងប្រទេសកម្ពុជា *ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ(LEMNA)* មិនបានធ្វើវិសោធនកម្មទេ ចាប់តាំងពីមានការបោះពុម្ពផ្សាយរបាយការណ៍របស់លោក នៅក្នុងខែកក្កដា ឆ្នាំ២០១២ បើទោះជាលោកបានផ្តល់អនុសាសន៍លើបញ្ហានេះរួចហើយក្តី។ ទោះជាយ៉ាងណាក៏ដោយ អ្នករាយការណ៍ពិសេសដឹងថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានខិតខំប្រឹងប្រែងពង្រឹងឯករាជ្យភាពរបស់ខ្លួន ដោយតែងតាំងចៅក្រមជាន់ខ្ពស់ដែលបានចូលនិវត្តន៍ ចំនួនពីររូបធ្វើជាសមាជិករបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប)។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ក៏បានទទួលយក

ផងដែរ នូវការស្នើសុំរបស់អង្គការសង្គមស៊ីវិល ដូចជាការហាមប្រាមការប្រើប្រាស់ធនធានរបស់រដ្ឋ មានដូចជារថយន្ត អាគារ និងសេវារបស់មន្ត្រីរាជការស៊ីវិល នៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ការផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់កន្លែងសាធារណៈ ដូចជាទីផ្សារសំរាប់ធ្វើយុទ្ធនាការឃោសនាបោះឆ្នោតដោយគណបក្សនយោបាយទាំងអស់ ការហាមប្រាមការដាក់ស្លាកសញ្ញាគណបក្ស និងឯកសារឃោសនាបោះឆ្នោតដែលគាំទ្រដល់គណបក្សនយោបាយជាក់លាក់ នៅក្នុង ឬនៅលើអគាររបស់រដ្ឋ។ ជាអកុសល កិច្ចខិតខំប្រឹងប្រែង ដែលស្វាគមន៍ទាំងនេះ បានលេចចេញជាករណីមួយចំនួននៃការជ្រៀតជ្រែកខាងនយោបាយពីសំណាក់មន្ត្រីរាជការស៊ីវិល ដែលនៅតែត្រូវបានគេរាយការណ៍ថាមាន។ ទោះជាបានសំដែងការធានាដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថា មន្ត្រីសាធារណៈមិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងយុទ្ធនាការឃោសនាសកម្មសំរាប់គណបក្សនយោបាយណាមួយ ក្នុងនាមជាមន្ត្រី នៅក្នុងអំឡុងពេលម៉ោងធ្វើការរបស់ខ្លួនក៏ដោយ  ការហាមប្រាមនេះមិនត្រូវបានគោរពយ៉ាងម៉ឺងម៉ាត់ដោយមន្ត្រីសាធារណៈពីថ្នាក់ទាបបំផុត ទៅដល់ថ្នាក់ខ្ពស់បំផុតរបស់រដ្ឋាភិបាលឡើយ។ បញ្ហានេះរិតតែកើតមានខ្លាំងថែមទៀត នៅតាមតំបន់ជនបទ។ អាស្រ័យហេតុនេះ អ្នករាយការណ៍ពិសេសចាំបាច់ត្រូវរំលឹកឡើងវិញថា គ្រប់មន្ត្រីរាជការស៊ីវិល នគរបាល និងយោធាទាំងអស់ មិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសកម្មភាពគាំទ្រ ដល់គណបក្សនយោបាយណាមួយឡើយ។ អ្នករាយការណ៍ពិសេសមានកង្វល់ផងដែរ អំពីបញ្ហាជាច្រើន ដែលលោកបានដឹងពីអង្គការឃ្លាំមើលការបោះឆ្នោត និងអង្គការសិទ្ធិមនុស្សឯករាជ្យមួយចំនួន។

៣៩. កង្វល់សំខាន់មួយ គឺសុចរិតភាពនៃដំណើរការចុះឈ្មោះអ្នកបោះឆ្នោត និងបន្ទាប់មក គឺបញ្ជីឈ្មោះអ្នកបោះឆ្នោត។ សវនកម្មពីរនៃបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបានធ្វើឡើងនៅដើមឆ្នាំ២០១៣ ដែលក្នុងនោះ មានសវនកម្មមួយត្រូវបានធ្វើឡើងដោយវិទ្យាស្ថានប្រជាធិបតេយ្យជាតិ(NDI) និងក្រុមឃ្លាំមើលការបោះឆ្នោត ហៅថា គណៈកម្មាធិការ អព្យាក្រឹត និងយុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា(NICFEC) និងសវនកម្មមួយផ្សេងទៀតធ្វើ ឡើងដោយគណៈកម្មាធិការ ដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា(COMFREL) បានបង្ហាញឱ្យដឹងពីគុណវិបត្តិដែលអាចប៉ះពាល់ដោយផ្ទាល់ដល់ការបោះឆ្នោត។ ទន្ទឹមនឹងអ្នករាយការណ៍ពិសេស មិនមានតួនាទីពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការរកឃើញទាំងនេះ លោកយល់ឃើញថាកង្វល់ទាំងនេះ ត្រូវបានកត់សំគាល់ ហើយប្រសិនជាសមស្រប គួរតែដោះស្រាយឲ្យបានត្រឹមត្រូវ ជាពិសេស ការរកឃើញទាំងនេះចេញមកពីប្រភពច្រើន។ សវនកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោត(VRA) របស់វិទ្យាស្ថានប្រជាធិបតេយ្យជាតិ(NDI) និងគណៈកម្មាធិការអព្យាក្រឹតនិងយុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា(NICFEC) បានរាយការណ៍ថា "ការធ្លាក់ចុះជារួម ក្នុងគុណភាពនៃបញ្ជីឈ្មោះអ្នកបោះឆ្នោត ចាប់តាំងពីឆ្នាំ២០០៨ ចំពោះភាពទូលំទូលាយ ភាពត្រឹមត្រូវ និងបច្ចុប្បន្នភាព” ។ របាយការណ៍នេះបង្ហាញថា អត្រាចុះឈ្មោះអ្នកបោះឆ្នោតបានថយចុះពី ៨៧.៩% នៃអ្នកមានសិទ្ធិបោះឆ្នោត ក្នុងឆ្នាំ២០០៨ ដល់ ៨២.៩% ក្នុងឆ្នាំ២០១៣ ហើយ "១០.៨% នៃពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត ដែលបានគិតថា ពួកគាត់បានចុះ ឈ្មោះរួចហើយ ប៉ុន្តែមិនមានឈ្មោះក្នុងបញ្ជីបោះឆ្នោត”  និងមិនអាចបោះឆ្នោតនៅថ្ងៃបោះឆ្នោតបាន។ សវនកម្មបានឲ្យដឹងផងដែរថា "មានតែ ៦៣.៦% នៃឈ្មោះនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតប៉ុណ្ណោះ ដែលអាចពិនិត្យផ្ទៀងផ្ទាត់ដោយផ្ទាល់បាន ដោយសារបច្ចុប្បន្ន គេរស់នៅកន្លែងដែលបានចុះឈ្មោះ រីឯអ្នកឆ្លើយតបមានចំនួន ១៧.៩% ប៉ុន្តែពេលវេលា ភាគច្រើន ពួកគេរស់នៅ

កន្លែងមួយទៀត និង ១០.៤% ទៀត មិនមានដោយផ្ទាល់ទេ" ។ ការស្ទង់មតិមួយទៀត ធ្វើឡើងដោយគណៈកម្មាធិការ ដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា(COMFREL) ដោយប្រើវិធីសាស្ត្រផ្សេងៗ បានឈានដល់ការសន្និដ្ឋានស្រដៀងគ្នានេះ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានប្រកាសថា សវនកម្មនេះ មិនអាចជឿទុកចិត្តបាន ដោយសារហេតុផលខាងវិធីសាស្ត្រ។ អ្នករាយការណ៍ពិសេស ត្រូវបានគេប្រាប់ឲ្យដឹងថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានជួលក្រុមហ៊ុនឯករាជ្យមួយឲ្យធ្វើសវនកម្មមួយទៀត នៃបញ្ជីឈ្មោះអ្នកបោះឆ្នោត។ សវនកម្មនោះ បានរកឃើញថា ៩.៧% នៃឈ្មោះអ្នកបោះឆ្នោតត្រូវបានបាត់ ដែលលទ្ធផលនេះប្រកៀកប្រកិតគ្នានឹងលទ្ធផលនៃសវនកម្មរបស់វិទ្យាស្ថានប្រជាធិបតេយ្យជាតិ(NDI) និងគណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា(NICFEC) និងគណៈកម្មាធិការ ដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)។ ទោះជាយ៉ាងណាក៏ដោយ តាមរយៈការពិនិត្យប្រៀបធៀបលទ្ធផលនេះ ជាមួយទិន្នន័យឯកជនរបស់ពួកគេ នៅទីបំផុត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានរាយការណ៍ថា មានតែ ៣ % នៃឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតប៉ុណ្ណោះ ដែលបានពិនិត្យឃើញថាមិនមាន។ អ្នករាយការណ៍ពិសេសមានការសោកស្ដាយដែលថា ដោយផ្អែកលើលទ្ធផលនៃសវនកម្មដំបូង ការកែតម្រូវបញ្ជីនេះ មិនបានធ្វើតាំងពីដើមមក ដែលនាំឲ្យប្រជាពលរដ្ឋមួយចំនួនធំ ប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោត។ អ្នករាយការណ៍ពិសេស សូមកោតសរសើរគំនិតផ្ដួចផ្ដើមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ក្នុងការធ្វើសវនកម្មដោយខ្លួនឯងផ្ទាល់ ដែលបានរកឃើញថាមានតែ ៣% នៃអ្នកមានសិទ្ធិបោះឆ្នោត ដែលអះអាងថាបានចុះឈ្មោះ ហើយមិនមានឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត។ លោកបានប្រកាន់ខ្ជាប់នូវទស្សនៈរបស់លោកថា មានតែការពិនិត្យតម្លាភាពលើបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលធ្វើឡើងតាមរយៈដំណើរការមួយ ដែលអនុញ្ញាតឱ្យមានការកែតម្រូវលើចំណុចដែលជាកំហុសឆ្គងនឹងកំណត់ឲ្យបានប្រាកដប្រជាថា ការដកចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត នឹងមិននាំទៅរកការបដិសេធសិទ្ធិបោះឆ្នោតរបស់អ្នកមានសិទ្ធិបោះឆ្នោតណាម្នាក់ឡើយ។ មានកង្វល់ថា ទំនុកចិត្តរបស់សាធារណជន នៅក្នុងដំណើរការ និងលទ្ធផលនៃការបោះឆ្នោតនេះ នឹងត្រូវបានធ្វើឲ្យខូច។

៤០. ដើម្បីឱ្យបញ្ជីឈ្មោះអ្នកបោះឆ្នោត អាចត្រូវបានពិនិត្យផ្ទៀងផ្ទាត់ទាន់ពេលវេលាសំរាប់ការបោះឆ្នោត សង្គមស៊ីវិល បានជំរុញឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅគ្រប់ភូមិទាំងអស់ ដើម្បីឲ្យអ្នកបោះឆ្នោតអាចងាយស្រួលពិនិត្យមើលឈ្មោះរបស់ខ្លួន និងរាយការណ៍អំពីភាពមិនប្រក្រតីណាមួយ ទៅគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោត(CEC) ដែលបន្ទាប់មកអាចពិនិត្យ និងកែតម្រូវបញ្ជីឈ្មោះអ្នកបោះឆ្នោត។ នៅក្នុងជំនួបប្រជុំរបស់លោកជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) អ្នករាយការណ៍ពិសេស បានលើកឡើងអំពីបញ្ហាទាំងនេះផងដែរ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានបញ្ជាក់ឡើងវិញពីការបដិសេធរបស់ខ្លួនចំពោះការបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅថ្នាក់ភូមិ ដោយលើកហេតុផលថា "ច្បាប់ បទបញ្ញា និងនីតិវិធី មិនបានចែងអំពីការបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅថ្នាក់ភូមិទេ"។[4] ទន្ទឹមនេះដែរ អ្នករាយការណ៍ពិសេស បានកត់សំគាល់

4 លិខិតរបស់ គ.ជ.ប លេខ 05.22/13 គ.ជ. ប / SG / PIB ចុះថ្ងៃទី៩ ខែឧសភា។

ថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានយល់ព្រមបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅថ្នាក់ឃុំ-សង្កាត់ រយៈពេលមួយខែមុនថ្ងៃបោះឆ្នោត និងបានស្នើបង្កើតឲ្យមានបណ្តាញទូរស័ព្ទខ្សែពិសេស (hotlines) និងការបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅលើគេហទំព័រ ដើម្បីសម្រួលដល់ការផ្ទៀងផ្ទាត់ឈ្មោះអ្នកបោះឆ្នោត។ លោកយល់ថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានចាត់វិធានការលើចំណុចទាំងពីរនេះ។ អ្នករាយការណ៍ពិសេស ទទួលស្គាល់អំពីការរីកចម្រើនធំៗដែលបានលើកឡើងនេះ ប៉ុន្តែលោកបានកត់សំគាល់ឃើញដែរថា ការរីកចម្រើនទាំងនោះនៅមិនទាន់គ្រប់គ្រាន់ ដើម្បីអាចធានាឲ្យការប្រើប្រាស់ងាយស្រួលនូវព័ត៌មានមូលដ្ឋាន សម្រាប់ប្រជាពលរដ្ឋភាគច្រើន ដែលរស់នៅតាមតំបន់ជនបទក្នុងប្រទេសកម្ពុជាឡើយ។

៤១. វិធានការមួយទៀតដែលបានស្នើឡើងដោយអង្គការសង្គមស៊ីវិល ដើម្បីធានាអព្យាក្រឹតភាព និងឯករាជ្យភាពនៃគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោត(CECs) គឺបង្កើតគណៈកម្មការពិសេសមួយទទួលបន្ទុកជ្រើសរើស និងទទួលស្គាល់ផ្លូវការដល់គណៈកម្មការឃុំ-សង្កាត់ រៀបចំការបោះឆ្នោត(CECs) និងមន្ត្រីបម្រើការនៅស្ថានីយបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលមានការចូលរួមពីសមាជិករបស់គណបក្សនយោបាយដែលមានអាសនៈនៅក្នុងរដ្ឋសភា។ សំណើនេះត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បដិសេធចោល។

៤២. លើសពីនេះទៀត អ្នករាយការណ៍ពិសេសកត់សំគាល់ថា ចំនួនសន្លឹកឆ្នោតបន្ថែមត្រូវបានបោះលើសលុប(២.៥ លានសន្លឹកច្រើនជាងចំនួនឈ្មោះអ្នកបោះឆ្នោតដែលបានចុះបញ្ជី)។ លោកបានសំដែងក្តីសង្ឃឹមថា រាល់សន្លឹកឆ្នោតនីមួយៗនេះ នឹងត្រូវបានពន្យល់ហេតុផលឲ្យបានច្បាស់លាស់ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ព្រោះថាការធ្វើដូច្នេះ អាចកាត់បន្ថយបានយ៉ាងច្រើននូវការបារម្ភនៅថ្ងៃខាងមុខអំពីលទ្ធផលនៃការបោះឆ្នោត។

៤៣. រយៈពេលប៉ុន្មានសប្តាហ៍បន្ទាប់ពីដំណើរទស្សនកិច្ចរបស់អ្នករាយការណ៍ពិសេស គេបានកត់សំគាល់ឃើញមានការបំភិតបំភ័យប្រឆាំងនឹងថ្នាក់ដឹកនាំគណបក្សប្រឆាំង តាមរយៈការប្រើប្រាស់វិធានការតាមផ្លូវច្បាប់ មានដូចជា ការបណ្តេញពួកគេចេញពីរដ្ឋសភា និងការប្រើប្រាស់ច្បាប់ ដើម្បីផ្តន្ទាទោសចំពោះសេចក្តីថ្លែងការណ៍ និងសកម្មភាពរបស់ពួកគេដែលត្រូវបានចោទប្រកាន់។

៤៤. នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៣ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាទាំង១២ រូប រួមមានសមាជិក សភានៃគណបក្សកាន់អំណាច(CPP) បានសម្រេចដកអភ័យឯកសិទ្ធិសមាជិកសភាចំនួន ២៩ រូបមកពីគណបក្សប្រឆាំង។ ទន្ទឹមនេះបញ្ហាអំពីនីត្យានុកូលភាពនៃសកម្មភាពនេះ បើកចំហសម្រាប់ការពិភាក្សាសកម្មភាពនេះឮខ្ទរខ្ទារថា ជាការបំភិតបំភ័យផ្នែកនយោបាយទៅលើគណបក្សប្រឆាំង។ សកម្មភាពនេះបន្ថែមលើការវិវដ្តជាច្រើនទៀត ដែលទំនងជាមានបំណងបំភិតបំភ័យតស្សូរជនគណបក្សប្រឆាំង។ ការបាត់បង់ឋានៈ ក៏ដូចជាការដកអភ័យឯកសិទ្ធិសភារបស់សមាជិកគណបក្សប្រឆាំង ធ្វើឲ្យប៉ះពាល់ដល់លទ្ធភាពរបស់ពួកគេ ក្នុងការនិយាយស្តីដោយសុវត្ថិភាព និងបើកផ្លូវឲ្យមានការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ។

៤៥. វិធានការផ្លូវច្បាប់ ជាពិសេស ការចោទប្រកាន់បទបរិហារកេរ្តិ៍ ឬបទញុះញង់ ត្រូវបានគេប្រើ ដើម្បីបង្ខូចកិត្តិយសរបស់គណបក្សប្រឆាំងដ៏ធំ គឺគណបក្សសង្គ្រោះជាតិ(CNRP)។ លោក កឹម សុខា ដែលជាប្រធានស្តីទីនៃគណបក្សសង្គ្រោះជាតិ(CNRP)រូបគាត់ផ្ទាល់បានជួបប្រទះភាពចម្រូងចម្រាសជាច្រើន ដែលបានផ្ទុះឡើងជាមានបណ្តឹង ដាក់ទៅតុលាការប្រឆាំងនឹងរូបគាត់ និងការគំរាមកំហែងច្រើនថែមទៀត។

៤៦. នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៣ សម្រង់ខ្សែអាត់ថតសំលេងចោទប្រកាន់លោក កឹម សុខា ត្រូវបានចេញផ្សាយដោយអង្គភាពព័ត៌មាន និងប្រតិកម្មរហ័សនៃទីស្តីការគណៈរដ្ឋមន្រ្តី ដែលបានអះអាងថា គុក ស-២១ ដ៏មហាព្រៃផ្សៃក្នុងរបបខ្មែរក្រហម ដែលគេស្គាល់ជាទូទៅផងដែរថាជាគុក "ទួលស្លែង" គឺជាគុកសិប្បនិម្មិត ដែលវៀតណាមជាអ្នកបង្កើតឡើង។ នៅថ្ងៃទី២៧ ខែឧសភា លោកនាយករដ្ឋមន្ត្រី បានអំពាវនាវឲ្យធ្វើសេចក្តីព្រាង និងអនុម័តច្បាប់ប្រឆាំងអ្នកមិនទទួលស្គាល់ឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម។ នៅថ្ងៃទី៧ ខែមិថុនា បន្ទាប់ពីការដកអភ័យឯកសិទ្ធិសភា របស់គណបក្សប្រឆាំងទាំងអស់រួចមក សមាជិកសភាដែលបានចូលរួមប្រជុំសភាចំនួន ៨៦ មកពីគណបក្សប្រជាជនកម្ពុជា និងគណបក្សចម្រុះរបស់ខ្លួន គឺគណបក្សហ៊្វុនស៊ិនប៉ិច បានអនុម័តជាឯកច្ឆ័ន្ទលើច្បាប់ស្តីការប្រឆាំងនឹងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ អ្នករាយការណ៍ពិសេស មានកង្វល់ជាខ្លាំងថាច្បាប់ដ៏សំខាន់មួយនេះ ត្រូវបានបោះឆ្នោតអនុម័តដោយគ្មានការពិភាក្សាដេញដោលជាសាធារណៈណាមួយ ទេ។

៤៧. វិស័យជាកង្វល់មួយទៀត គឺជាការរិតត្បិតសេរីភាពក្នុងការបញ្ចេញមតិ។ គណបក្សកាន់អំណាចបានគ្រប់គ្រង ស្ទើរតែផ្តាច់មុខលើវិទ្យុ និងទូរទស្សន៍ជាតិនៅក្នុងប្រទេស។ ប្រជាពលរដ្ឋភាគច្រើនលើសលុប នៅតាមតំបន់ជនបទមានលទ្ធភាពតិចតួចក្នុងការទទួលបានព័ត៌មានឯករាជ្យ ក្រៅតែពីទទួលបានតាមរយៈកម្មវិធីផ្សព្វផ្សាយដោយវិទ្យុបរទេស។ នៅថ្ងៃទី២៨ ខែមិថុនា ក្រសួងព័ត៌មានបានចេញសេចក្តីណែនាំចំនួនពីរ មានទិសដៅហាមប្រាមវិទ្យុបរទេសទាំងអស់ ធ្វើការផ្សព្វផ្សាយក្នុងអំឡុងពេលបោះឆ្នោត។ សេចក្តីណែនាំមួយ ចុះហត្ថលេខានៅថ្ងៃទី២៥ ខែមិថុនា ចែងថា គ្រប់ស្ថានីយវិទ្យុ FM ត្រូវផ្អាកការផ្សាយបន្តពីវិទ្យុបរទេស ដែលផ្សាយជាខេមរភាសាទាំងអស់ ក្នុងរយៈពេលបើកការឃោសនា សាមសិបមួយ(៣១)ថ្ងៃមុនថ្ងៃបោះឆ្នោត និងបានចែងបន្ថែមទៀតថា ករណីស្ថានីយវិទ្យុ FM ណាមិនគោរពតាមសេចក្តីណែនាំនេះ ក្រសួងព័ត៌មាននឹងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។ សេចក្តីណែនាំទីពីរ ចុះថ្ងៃទី២១ ខែមិថុនា បានបង្គាប់ឱ្យបញ្ឈប់ការផ្សព្វផ្សាយ និងការផ្សាយបន្តដោយផ្ទាល់ពីស្ថានីយវិទ្យុបរទេសទាំងអស់អំពីការស្ទង់មតិ ឬលទ្ធផលនៃការស្ទង់មតិ ដែលទាក់ទងនឹងដំណើរការបោះឆ្នោត ក្នុងរយៈពេលប្រាំថ្ងៃមុនថ្ងៃបោះឆ្នោត និងបញ្ឈប់ការផ្សព្វផ្សាយពីសកម្មភាពឃោសនាអ្វីទាំងអស់អំឡុងពេល ២៤ ម៉ោងចុងក្រោយ មុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត។ ចាប់ពីត្រឹមថ្ងៃនោះមក ការហាមប្រាមនេះអនុវត្តភ្លាមៗចំពោះការផ្សាយជាខេមរភាសាតាមស្ថានីយវិទ្យុបរទេសជាច្រើន ដែលប្រព័ន្ធផ្សព្វផ្សាយ និងអង្គការសង្គមស៊ីវិលនានាថាជាប្រភពដ៏សំខាន់នៃព័ត៌មានឯករាជ្យ។ នៅថ្ងៃទី២៩ ខែមិថុនា ក្រសួងព័ត៌បានចេញសេចក្តីកែតម្រូវសេចក្តីណែនាំទីមួយ ប៉ុន្តែនៅរក្សាទុកសេចក្តីណែនាំទីពីរ។ អ្នករាយការណ៍ពិសេស បញ្ជាក់ថា ការធានាឲ្យសាធារណជនមានលទ្ធភាពទទួលបានព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ គឺជាកត្តាសំខាន់ជាសារវ័ន្ត សំរាប់ធានាការប្រកួតប្រជែងដោយស្មើភាពគ្នាក្នុងដំណើរការបោះឆ្នោត និងអនុញ្ញាតឱ្យអ្នកបោះឆ្នោត ធ្វើការជ្រើសរើសគណបក្សណាមួយ

ក្រោយពីទទួលបានព័ត៌មានគ្រប់គ្រាន់។ លោកស្វាគមន៍ចំពោះការលុបចោល សេចក្តីណែនាំ ចុះថ្ងៃទី២៥ ខែមិថុនា ប៉ុន្តែលោកមានការសោកស្តាយដែលថា សេចក្តីណែនាំចុះថ្ងៃទី២១ នៅមិនទាន់បានលុបចោលនៅឡើយ។ អ្នករាយការណ៍ពិសេស បានផ្តល់អនុសាសន៍យ៉ាងមុតមាំថា គំនិតផ្តួចផ្តើមទាំងនេះ ដែលមិនមានចែងក្នុងច្បាប់ ហើយបំពានសេរីភាពខាងព័ត៌មាន និងការសំដែងមតិ នឹងត្រូវបានហាមឃាត់ប្រកបដោយមានប្រសិទ្ធភាពនៅពេលអនាគត។

## VI. ការតាមដានការអនុវត្តអនុសាសន៍ ស្តីពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត

៤៨. ពាក់ព័ន្ធនឹងអនុសាសន៍ក្នុងរបាយការណ៍ស្តីពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត ដែលបានដាក់ ជូនសម័យប្រជុំលើកទីម្ភៃមួយនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ក្នុងឆ្នាំ២០១២ (A/HRC/21/63 /Add.1) អ្នករាយការណ៍ពិសេស កត់សំគាល់អំពីការវិវឌ្ឍជាវិជ្ជមាន ដែលកើតចេញពីកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិលើដីឯក ជនរបស់រដ្ឋាភិបាល ដែលដឹកនាំដោយលោកនាយករដ្ឋមន្ត្រីផ្ទាល់។ ក្នុងអំឡុងពេលបំពេញទស្សនកិច្ចរបស់លោកទៅកាន់ខេត្តកំពង់ឆ្នាំង នៅក្នុងខែធ្នូ ឆ្នាំ២០១២ អ្នករាយការណ៍ពិសេសបានជួបពិភាក្សាផ្ទាល់ជាមួយ ប្រជាពលរដ្ឋដែលទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីរបស់ខ្លួន ក្រោយពីបានរង់ចាំអស់រយៈពេលដ៏យូរមកហើយ។ ព្រមជាមួយគ្នានឹងភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិជាច្រើនទៀត អ្នករាយការណ៍ពិសេស បានអំពាវនាវយូរមក ហើយឱ្យពន្លឿនការអនុវត្តកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ហើយលោកមានសេចក្តីរីករាយ ដោយឃើញសកម្មភាពនេះ បានស្តែងចេញនាពេលនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តបន្តនៃក្របខណ្ឌដែលមានស្រាប់ស្តីពីសិទ្ធិដីធ្លី និងការពង្រឹងស្ថាប័នការគ្រប់គ្រងដីធ្លី គឺជាការចាំបាច់ដើម្បីឲ្យសមិទ្ធផលទាំងនេះមាន និរន្តរភាព ហើយអនុសាសន៍ជាច្រើនទៀត នៅមិនទាន់បានដោះស្រាយគ្រប់គ្រាន់នៅឡើយ។

៤៩. ការកាន់កាប់ដីគ្មានសុវត្ថិភាព ប្រព័ន្ធគ្មានប្រសិទ្ធភាព (តុលាការ និងសុរិយោដី) ក្នុងការដោះស្រាយបណ្តឹងទាមទារទាក់ទងទៅនឹងដីធ្លី និងឧបសគ្គដទៃទៀតចំពោះសិទ្ធិទទួលបានយុត្តិធម៌ និងទំនាស់ដីធ្លីដែលរីករាលដាល នៅតែជាបញ្ហាប្រឈមដដែល។ ចំនួនប៉ះទង្គិចគ្នានៅតែបន្តមានរវាងអាជ្ញាធរ (ជនស៊ីវិល និងយោធា)  តំណាងក្រុមហ៊ុន ដែលពាក់ព័ន្ធនឹងវិស័យកសិ-ឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងការអភិវឌ្ឍវិស័យអចលនវត្ថុ (រាប់ទាំងបុគ្គលិក សន្តិសុខឯកជន) ជាមួយសហគមន៍ដែលរងផលប៉ះពាល់ គឺជាក្តីកង្វល់មួយ ជាពិសេស ដោយសារចំនួននៃឧប្បត្តិហេតុ មួយចំនួនពាក់ព័ន្ធនឹងការប្រើប្រាស់គ្រាប់ពិត និងអំពើហិង្សាផ្សេងទៀត។ អ្នកការពារសិទ្ធិមនុស្ស ដែលបានធ្វើការក្នុងវិស័យអប់រំសិទ្ធិដីធ្លី និងការតស៊ូមតិ និងបុគ្គលទាំងឡាយ ដែលធ្វើការទាមទារសិទ្ធិដីធ្លី នៅតែបន្តរងការធ្វើទុក្ខបុកម្នេញ ហើយសិទ្ធិសេរីភាពក្នុងការសំដែងមតិ និងសិទ្ធិជួបប្រជុំទៀតសោធ ត្រូវបានបន្ថយជាបន្តបន្ទាប់។

៥០. កាលពីពេលធ្វើរបាយការណ៍មុន សកម្មជន (ដែលភាគច្រើនជាស្ត្រី) ដែលពាក់ព័ន្ធនឹងទំនាស់ដីធ្លីនៅតំបន់បឹងកក់ និងសហគមន៍បុរីកីឡា បានបន្តស្ថិតនៅជួរមុខនៃការតវ៉ាជាប្រចាំ ដោយមានករណីគ្រួសារប្រជាពលរដ្ឋជាច្រើន ដែលត្រូវបានគេបណ្តេញចេញនោះ ពុំទាន់បានដោះស្រាយនៅឡើយ ដោយសាលារាជធានីភ្នំពេញ ក្រុមហ៊ុនស៊ូកាគូ  អ៊ីញ (Shukaku Inc.)  និងក្រុមហ៊ុនផានអ៊ីម៉ិច (Phan Imex) នៅ

ឡើយទេ។ តំណាងសហគមន៍មួយចំនួនបានទទួលរងការគំរាមកំហែង ដោយគម្រោងពង្រីកព្រលានយន្តហោះអន្តរជាតិភ្នំពេញ បានធ្វើការតវ៉ាជាប្រចាំផងដែរ ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ រាជធានីភ្នំពេញនៅតែជាកន្លែងមួយនៃការតវ៉ា ការធ្វើបាតុកម្មជាប្រចាំ ហើយប្រការដែលគួរឲ្យសោកស្តាយនោះ គឺអំពើហិង្សាកើតមានរវាងសហគមន៍ និងនគរបាល រាប់ទាំងបច្ចុប្បន្ននេះ មានការប្រើប្រាស់ខែលឆក់ និងកាណុងបាញ់ទឹក ដើម្បីបំបែកក្រុមបាតុករ ដោយអាជ្ញាធរ។ ក្នុងករណីខ្លះ សាលារាជធានីភ្នំពេញបានដាក់ពង្រាយបុគ្គលិកសន្តិសុខឯកជនឲ្យប្រឈមមុខជាមួយក្រុមបាតុករ និងការឃុំខ្លួនសកម្មជន។ ស្ត្រីពីរនាក់ដែលជាសកម្មជនផ្នែកលំនៅដ្ឋាន ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ ដោយសារតែត្រូវបានគេជឿ និងកំណត់ជាគោលដៅជាអ្នកទាមទារសិទ្ធិរបស់ពួកគាត់។ ស្ត្រីទាំងពីររូបនោះ ម្នាក់ឈ្មោះ អ្នកស្រី ទឹម សាក់មុន្នី ជាតំណាងអ្នកបុរីកីឡា និងម្នាក់ទៀត ឈ្មោះ អ្នកស្រី យ៉ោម បុប្ផា សកម្មជនដីបឹងកក់។ សាលាឧទ្ធរណ៍បានសម្រេចព្យួរទោសអ្នកស្រី ទឹម សាក់មុន្នី បន្ទាប់ពីអ្នកស្រីបានទទួលទោសពន្ធនាគាររយៈពេលបីខែរួចមក ចំណែក អ្នកស្រី យ៉ោម បុប្ផា នៅតែត្រូវជាប់ពន្ធនាគារដដែល បន្ទាប់ពីសវនាការនៅសាលាឧទ្ធរណ៍។

៥១. ប្រជាពលរដ្ឋដែលត្រូវបានបណ្តេញចេញ និងបានតាំងទីលំថ្មី ត្រូវបានគេរាយការណ៍ថា បានទទួលរងស្ថានភាពរស់នៅក្រលំបាក (រាប់ទាំងសំណង់លំនៅដ្ឋានមានស្តង់ដាទាប និងទឹកគ្មានសុវត្ថិភាព និងស្ថានភាពអនាម័យ) និងឱកាសរកការងារធ្វើមិនគ្រប់គ្រាន់ គួបផ្សំនឹងលទ្ធភាពនៅមានកម្រិតក្នុងការទទួលបានសេវាសុខភាព និងការអប់រំ។ ទីតាំងថ្មីនៅបន្តរៀបចំផែនការ និងអភិវឌ្ឍមិនបានល្អមុនការបណ្តេញចេញ ហើយការសន្យាដោយក្រុមហ៊ុនពាក់ព័ន្ធ និងសាលារាជធានី ពុំបានគោរពតាមជាច្រើនលើកច្រើនសារមកហើយ។ ទីតាំងថ្មីនៅតំបន់ភ្នំបាតមានប្រជាពលរដ្ឋជាងមួយរយគ្រួសារ មកពីសហគមន៍បុរីកីឡា រាប់ទាំងប្រជាពលរដ្ឋ ដែលត្រូវបានគេបណ្តេញចេញដោយបង្ខំ ក្នុងខែមករា ឆ្នាំ២០១២ មានអភិវឌ្ឍមួយផ្នែក តាមរយៈការជួយឧបត្ថម្ភពីម្ចាស់ជំនួយ ប៉ុន្តែជំនួយពីក្រុមហ៊ុនផានអ៊ីម៉ិច) Phan Imex) និងសាលារាជធានីភ្នំពេញ គឺមានចំនួនតិចតួចបំផុត។

៥២. ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ឃើញមានការរីកចម្រើនតិចតួច ក្នុងដោះស្រាយឫសគល់នៃបញ្ហាជម្លោះដីធ្លី នៅរាជធានីភ្នំពេញ និងនៅទីក្រុងធំៗដទៃទៀត និងសិទ្ធិទទួលបានយុត្តិធម៌ ហើយការដោះស្រាយសមស្រប នៅតែជាកង្វល់គួរឲ្យកត់សំគាល់ដដែល។ ឧទាហរណ៍ ការបណ្តេញចេញដោយបង្ខំក្នុងខែមីនា ឆ្នាំ២០១៣ នៅខេត្តព្រះសីហនុ ធ្វើឲ្យប៉ះពាល់ដល់ប្រជាពលរដ្ឋ ២១ គ្រួសារ ខណៈពេលដែលបណ្តឹងឧទ្ធរណ៍កំពុងចាត់ការនៅតុលាការ។ នៅទីបំផុត បញ្ហានេះត្រូវបានដោះស្រាយ បន្ទាប់ពីមានបាតុកម្មមួយធ្វើឡើងដោយប្រជាពលរដ្ឋជាច្រើនគ្រួសារ នៅរាជធានីភ្នំពេញ និងបន្ទាប់មកមានអន្តរាគមន៍ពីលោកនាយករដ្ឋមន្ត្រី។ ដូចបានគូសបញ្ជាក់ពីមុន ឧបសគ្គមួយចំនួន ដូចជា ពេលវេលាយូរនៃដំណើរការរដ្ឋបាល និងនីតិវិធីតុលាការ ការចំណាយហិរញ្ញវត្ថុសំរាប់ដាក់ពាក្យបណ្តឹង ភាពមិនស្មើគ្នានៃអំណាច និងការជ្រៀតជ្រែកខាងនយោបាយ បាននាំឱ្យមានការប្រើប្រាស់តុលាការមិនស៊ីសង្វាក់គ្នា។

៥៣. នៅតាមតំបន់ជនបទ អ្នករាយការណ៍ពិសេសត្រូវបានលើកទឹកចិត្ត ដោយឃើញយុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីឯកជនពីដីរដ្ឋ (រាប់ទាំងសម្បទានដីសេដ្ឋកិច្ច និងសម្បទានព្រៃឈើ និងដីដទៃផ្សេងទៀតដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន) ដែលជាការផ្តួចផ្តើមគំនិតដោយលោកនាយករដ្ឋមន្ត្រី ក្រោមការជួយ

ឧបត្ថម្ភគាំទ្រពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងខែមិថុនា ឆ្នាំ២០១២ ដែលបាន រាយការណ៍ស្ថិតិសរុប នៅលើគេហទំព័ររបស់ខ្លួន។ យុទ្ធនាការនេះអនុវត្តតាមបទបញ្ជាដែលដាក់ចេញឲ្យផ្អាក ជាបណ្តោះអាសន្ននូវការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មី(ELCs) និងការពិនិត្យឡើងវិញ នូវសម្បទានដែលមាន ស្រាប់នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ ប៉ុន្តែវឌ្ឍនភាពពេញលេញនៃការពិនិត្យឡើងវិញនេះ មិនបានដឹងនៅ ឡើយទេ។ នៅក្នុងខែសីហា ឆ្នាំ២០១២ អ្នករាយការណ៍ពិសេសបានផ្ញើលិខិតមួយច្បាប់ ទៅក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ ដោយគូសបញ្ជាក់អំពីកង្វល់បឋមមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តបទបញ្ជា នេះ និងទទួលស្គាល់ការឆ្លើយតបលំអិត ដែលបានផ្តល់ជូនលោក ដោយក្រសួងនេះ នៅក្នុងខែកញ្ញា ឆ្នាំ ២០១២។ អ្នករាយការណ៍ពិសេសកត់សំគាល់ផងដែរថា បើទោះជាមានសម្បទានដីសេដ្ឋកិច្ចថ្មី(ELCs) មួយ ចំនួនបានចុះក្នុង រាជកិច្ចចាប់ពីខែឧសភា ដល់ខែធ្នូ ឆ្នាំ២០១២ ហើយក្តី ក៏សម្បទានដីសេដ្ឋកិច្ចថ្មី(ELCs) មួយចំនួនទៀត មិនបានចុះដែរ នៅក្នុងអំឡុងឆមាសទីមួយ ឆ្នាំ២០១៣ នេះ។

៥៤. ការផ្តល់ និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត គឺជាកម្មវត្ថុនៃដំណើរ បេសកកម្មក្នុង ខែឧសភាឆ្នាំ២០១២ របស់អ្នករាយការណ៍ពិសេស និងរបាយការណ៍តាមផែនការ ដែលត្រូវ ដាក់ជូនសម័យប្រជុំលើកទី២១ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។[5] គោលបំណងនៃរបាយការណ៍នេះ ដែលបាន ធ្វើបន្ទាប់ពីរបាយការណ៍ឆ្នាំ២០០៤ និងឆ្នាំ២០០៧ របស់អ្នកទទួលបានអាណត្តិមុនៗ ស្តីពីផែនការនេះ គឺ ដើម្បីលើកកំពស់ការយល់ដឹងអំពីកង្វះភាពស្របគ្នាជាមួយក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដែលគ្រប់ គ្រងលើការផ្តល់ និងការគ្រប់គ្រងសម្បទានដី ព័ត៌មានស្តីពីការប្រើប្រាស់តំបន់ការពារ (ទីតាំង ទំហំ ការប្រើ ប្រាស់) និងកង្វះភស្តុតាងអំពីអត្ថប្រយោជន៍ខាងសេដ្ឋកិច្ចនៃសម្បទានដីសំរាប់ប្រជាពលរដ្ឋកម្ពុជាភាគច្រើន។

៥៥. ចាប់តាំងពីការដាក់របាយការណ៍ ឆ្នាំ២០១២ ស្តីពីសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃ ទៀត របស់អ្នករាយការណ៍ពិសេស ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានធ្វើឱ្យរីកចម្រើនក្នុង ការព្យាយាមដោះស្រាយវិវាទដីធ្លីដ៏រ៉ាំរ៉ៃ និងធ្វើឲ្យប្រសើរឡើងដល់សុវត្ថិភាពក្នុងការកាន់កាប់សំរាប់គ្រួសារ ប្រជាពលរដ្ឋដែលរស់នៅលើ និងជុំវិញតំបន់សម្បទានដី ដោយផ្តល់ធនធានមនុស្ស និងហិរញ្ញវត្ថុ ដើម្បីធ្វើការ វាស់វែងដី និងផ្តល់ប័ណ្ណកម្មសិទ្ធិ។ ទោះជាយ៉ាងណាក៏ដោយ មានការរីកចម្រើនតិចតួចលើការបង្កើតប្រព័ន្ធ ឲ្យកាន់តែប្រសើរសំរាប់ការផ្តល់ការគ្រប់គ្រង និងការធ្វើបញ្ជីរាយឈ្មោះសម្បទានដីសេដ្ឋកិច្ច និងសម្បទានដី ដទៃទៀត ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រសួងដទៃទៀត ព្រមទាំងបញ្ហាអំពីសិទ្ធិទទួល បានព័ត៌មាន និងតម្លាភាព ដែលបានគូសបញ្ជាក់នៅក្នុងរបាយការណ៍របស់លោក នៅតែជាបញ្ហាកង្វល់ ដដែល។

៥៦. ទោះបីជាមានការរីកចម្រើនក្នុងការចុះបញ្ជីដីធ្លីនៅតំបន់ជនបទ ក្រោមគំនិតផ្តួចផ្តើមរបស់ នាយករដ្ឋមន្ត្រីក្តី ក៏នៅមានកង្វល់មួយចំនួនទៀតអំពីដំណើរការនេះផងដែរ។ កង្វល់ដំបូងបង្អស់ គឺជាទំនាក់ ទំនងដែលគេរាយការណ៍ថាបានធ្វើឡើងដោយអាជ្ញាធរ តាមរបៀបបង្ខិតបង្ខំរវាងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី

---

[5] "ការវិភាគអំពីផលប៉ះពាល់លើសិទ្ធិមនុស្សដោយសម្បទានដី នៅក្នុងប្រទេសកម្ពុជា" A/HRC/21/63/Add.1/Rev.1 ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ ។

និងលទ្ធផល នៃការបោះឆ្នោត។ម្យ៉ាងវិញទៀត វាមិនច្បាស់លាស់ ឧទាហរណ៍ ថាតើហេតុអ្វីបានជាដីមួយចំនួនត្រូវបានធ្វើការវាស់វែង ហើយដីមួយចំនួនទៀត ត្រូវបានគេកាត់ចេញ។ ការនេះបានបណ្តាលឲ្យសហគមន៍មួយចំនួនធ្វើ ការប្តឹងតវ៉ាទៅនាយករដ្ឋមន្ត្រីដោយផ្ទាល់។ ឧទាហរណ៍ ដីរបស់សហគមន៍ទាំងឡាយដែលជាប់ដីចំការអំពៅ ដែលទទួលប្រយោជន៍ពីកិច្ចព្រមព្រៀងអនុគ្រោះពន្ធពាណិជ្ជកម្មពីសហភាពអឺរ៉ុប (អ្វីៗគ្រប់យ៉ាង លើកលែង តែ អាវុធ) នៅខេត្តកោះកុង  ឧត្តរមានជ័យ និងកំពង់ស្ពឺ បានរាយការណ៍ថា ដីរបស់ពួកគេ នៅមិនទាន់ត្រូវបានវាស់វែងនៅឡើយទេ។ លើសពីនេះទៀត អង្គការមិនមែនរដ្ឋាភិបាលដែលជារឿយៗ បំពេញចន្លោះ ប្រហោងក្នុងការពន្យល់អំពីសិទ្ធិ និងនីតិវិធីទៅសហគមន៍នានា ត្រូវបានគេរាំងមិនឲ្យតាមឃ្លាំមើលដំណើរការនេះ ដែលរួមចំណែកធ្វើឲ្យមានការយល់ច្រឡំនៅក្នុងករណីមួយចំនួន។ លើសពីនេះទៀត មានសេចក្តី រាយការណ៍អំពីការចូលទន្ទ្រានដោយសម្បទានិកទៅលើដី ដែលកំពុងស្ថិតក្នុងដំណើរការនៃការផ្តល់ប័ណ្ណកម្ម សិទ្ធិ ឧទាហរណ៍ ក្រុមហ៊ុនភាពីម៉ិច) Pheapimex) ក្នុងខេត្តពោធិសាត់ និងក្រុមហ៊ុនកៅស៊ូ អ៊ាលែវ) Kao Su Ea Lev) ក្នុងខេត្តរតនគីរី (ដែលពាក់ព័ន្ធនឹងជនជាតិដើមភាគតិចចារ៉ាយ)។ ក្នុងករណីខ្លះ ទំនាស់កើតចេញជាអំពើហិង្សា ដូចជា ពាក់ព័ន្ធនឹងការប៉ះទង្គិចគ្នាមួយរវាងតំណាងក្រុមហ៊ុនចំការកៅស៊ូ អឹម ឌី និងយោធា នៅ ខេត្តរតនៈគីរី ដែលបណ្តាលឲ្យសមាជិកសហគមន៍រងរបួសជាច្រើនកន្លែង។

៥៧. វាទំនងជារដ្ឋាភិបាល ដែលយ៉ាងហោចណាស់សម្រាប់រយៈពេលមួយដ៏ខ្លី ធ្វើឱ្យមានវឌ្ឍនភាពយឺតៗប៉ុណ្ណោះ ទៅលើការអនុវត្តក្របខ័ណ្ឌច្បាប់ក្នុងស្រុកដែលល្អ ដែលទទួលស្គាល់សិទ្ធិជនជាតិដើមភាគតិចក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព។ យ៉ាងហោចណាស់ ក្នុងរយៈពេលមួយដ៏ខ្លី វាទំនងជាថា កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ជនជាតិដើមភាគតិច ត្រូវបានកំណត់ថាជាបញ្ហាមិនអាទិភាពទៅវិញ ហើយធនធាននេះត្រូវបានបង្វែរពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់វិញ។ មានសេចក្តីរាយការណ៍ពីការគំរាមកំហែង ការយាយីរំខាន និងការបង្ខិតបង្ខំជនជាតិដើមភាគតិចក្នុងករណីមួយចំនួន និងករណីផ្សេងទៀត មានការយល់ច្រឡំក្នុងចំណោមបុគ្គលជនជាតិដើមភាគតិចមួយចំនួន ដែលបានជ្រើសយកប័ណ្ណកម្មសិទ្ធិដីឯកជន ដោយមិនបានយល់ដឹងពេញលេញពីសិទ្ធិរបស់ខ្លួនក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិដីសហគមន៍។ ភូមិដែលរងផលប៉ះពាល់ រាប់ទាំងជនជាតិដើមភាគតិច សួយ ក្នុងខេត្តកំពង់ស្ពឺ ជនជាតិដើមភាគតិច ចារ៉ាយ ទំពួន គ្រឹង និងកាចាក់ ក្នុងខេត្តរតនៈគីរី ជនជាតិដើមភាគតិច ព្នង និងស្ទៀង ក្នុងខេត្តមណ្ឌលគីរី និងជនជាតិដើមភាគតិចគួយ ក្នុងខេត្តព្រះវិហារ។

៥៨. ករណីដែលជាកង្វល់មួយទៀត ទាក់ទងនឹងការសាងសង់ទំនប់វារីអគ្គិសនី ដោយក្រុមហ៊ុនហាយដ្រូ ផៅវើ ឡូវើ សេសាន ក្រោម ២ ខូអិលធីឌី (ក្នុងភាពជាដៃគូរវាងក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប ខេមបូឌា និងក្រុមហ៊ុនចិន Hydrolancang International Energy Co. Ltd. និងក្រុមហ៊ុនវៀតណាម អ៊ីវីអិន អ៊ីនធីណេសិនណល យន់ស្តុក ) EVN Int'l Joint Stock Company) ត្រូវបានគេរាយការណ៍ថា មិនមានការពិគ្រោះយោបល់គ្រប់គ្រាន់ អំពីផលប៉ះពាល់បរិស្ថាន សេដ្ឋកិច្ច និងសង្គមលើគម្រោងនេះ អំពីការផ្តល់សំណង និងអំពីគម្រោងតាំងទីលំនៅថ្មី។ អ្នករាយការណ៍ពិសេសបានទៅទស្សនាសហគមន៍ទាំងនេះ នៅក្នុងខែឧសភា ឆ្នាំ២០១២ និងបានស៊ើបអង្កេតបណ្តឹងរបស់ពួកគេ។ រដ្ឋសភាបានអនុម័តយល់ព្រមលើការធានាផ្តល់ជំនួយគាំទ្រផ្នែក

ហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោង និងការសាងសង់ ដែលត្រូវបានរាយការណ៍ថាអាចកើតមាននៅថ្ងៃខាងមុខ ប៉ុន្តែសហគមន៍ខ្វះព័ត៌មានអំពីគម្រោងទាំងនេះ ប៉ុន្តែពួកគេពុំទាន់បានយល់ព្រមទទួលយកលក្ខខណ្ឌដោះស្រាយសមស្រប និងការតាំងទីលំនៅថ្មី។

៥៩. នៅទីបំផុត ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ មានករបង្កើតច្បាប់មួយចំនួន។ អ្នករាយការណ៍ពិសេសត្រូវបានគេប្រាប់ឲ្យដឹងថា សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ដីកសិកម្ម កំពុងស្ថិតក្រោមការពិនិត្យឡើងវិញ ហើយសង្ឃឹមថានឹងមានការពិគ្រោះយោបល់ដែលមានអ្នកពាក់ព័ន្ធច្រើនថែមទៀតចូលរួម ដែលដឹកនាំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការឧបត្ថម្ភគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី។ លោកត្រូវបានគេលើកទឹកចិត្ត ដោយសារដំណើរការពិគ្រោះយោបល់សម្រាប់សេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថានដែលដឹកនាំដោយក្រសួងបរិស្ថាន ដោយមានការឧបត្ថម្ភគាំទ្រពីការិយាល័យមេធាវីការពារផលប្រយោជន៍សាធារណៈ។ លោកមានការសោកស្តាយដែលថាសេចក្តីព្រាងគោលនយោបាយស្តីពីលំនៅដ្ឋានដែលបានរង់ចាំអស់រយៈពេលជាច្រើនឆ្នាំមកហើយនោះ នៅតែមិនទាន់បានបញ្ចប់និងអនុម័តយល់ព្រមដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅឡើយ។

## VII. សេចក្តីសន្និដ្ឋាន

៦០. អស់រយៈពេលបួនឆ្នាំហើយចាប់តាំងពីអ្នករាយការណ៍ពិសេសបច្ចុប្បន្ន បានទទួលតំណែងរបស់លោកបន្ទាប់ពី មានការតែងតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅខែមីនា ឆ្នាំ២០០៩។ នៅក្នុងអំឡុងពេលនេះ លោកបានមើលឃើញថាប្រទេសនេះបានធ្វើដំណើរឆ្ពោះទៅមុខនៅក្នុងវិស័យមួយចំនួន។ ប្រទេសកម្ពុជាគឺជាប្រទេសកំពុងបោះជំហានទៅមុខ ដែលបានទទួលផលប្រយោជន៍យ៉ាងច្រើនពីការងាររបស់អង្គការសង្គមស៊ីវិល ដែលបានផ្តល់បំពេញបន្ថែមដល់ប្រជាពលរដ្ឋនូវសេវា ដែលផ្តល់ដោយរដ្ឋាភិបាល ជាពិសេសសេវាណាដែលរដ្ឋាភិបាលបានផ្តល់មិនគ្រប់គ្រាន់។ សង្គមស៊ីវិលកាន់តែមានសកម្មភាពដ៏រស់រវើកនៅក្នុងវិស័យជាច្រើន ក្នុងនោះរួមមានការការពារសិទ្ធិមនុស្សផងដែរ។ ដូចបានលើកឡើងនៅក្នុងកថាខ័ណ្ឌខាងលើៗ បន្ទាប់ពីបានបង្ហាញរបាយការណ៍សំខាន់ៗចំនួនបួន ស្តីពីកំណែទម្រង់ប្រព័ន្ធតុលាការ សភា និងការបោះឆ្នោត និងរបាយការណ៍ស្តីពីផលប៉ះពាល់ដល់សិទ្ធិមនុស្សដោយសារសម្បទានដីសេដ្ឋកិច្ច និង សម្បទានដីផ្សេងទៀត ដោយក្នុងរបាយការណ៍នីមួយៗនោះមានភ្ជាប់នូវអនុសាសន៍ជាបន្តបន្ទាប់ អ្នករាយការណ៍ ពិសេស បានផ្តោតការយកចិត្តទុកដាក់លើការត្រួតពិនិត្យតាមដានការអនុវត្តអនុសាសន៍របស់លោក ក្នុងដំណើរបេសកកម្មពីរលើកចុងក្រោយរបស់លោក។ ទន្ទឹមនឹងមានការរីកចម្រើនគួរឲ្យលើកទឹកចិត្តនៅក្នុងវិស័យមួយចំនួនដូចបានលើកឡើងក្នុងរបាយការណ៍នេះ  ការរីកចម្រើននៅក្នុងវិស័យមួយចំនួនផ្សេងទៀត នៅតែមានការយឺតយ៉ាវ ដែលតាមស្ថានភាពមិនត្រូវមានបែបនេះ ហើយការរីកចម្រើននៅក្នុងវិស័យមួយចំនួននៅមានភាពគួរឲ្យបារម្ភ។

៦១. ការអត់ឱនអធ្យាអាស្រ័យគឺជាមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ។ ប៉ុន្តែ កម្រិតការអត់ឱនអធ្យាអាស្រ័យរបស់រដ្ឋាភិបាល ហើយសមត្ថភាពយកចិត្តទុកដាក់ចំពោះការរិះគន់ ក្នុងន័យស្ថាបនា អំពីសេចក្តីសម្រេចលើគោលនយោបាយ និងភាពខ្វះខាតរបស់រដ្ឋាភិបាលទំនងនឹងមានការថយចុះ។ លទ្ធិប្រជាធិបតេយ្យគឺជាការពិភាក្សា ហើយការពិភាក្សានោះបាត់បង់ ជាពិសេស ការពិភាក្សារវាងរដ្ឋាភិបាល និងគណបក្ស

ប្រឆាំង។ ការដឹកនាំនយោបាយជាការបង្កើតការព្រមព្រៀងគ្នាលើបញ្ហាដែលមានសារៈសំខាន់សំរាប់ប្រទេសជាតិ តាមរយៈការពិភាក្សា និងការបង្រួបបង្រួម។ អ្នករាយការណ៍ពិសេស បាន ជំរុញឲ្យមានការសម្របសម្រួលផ្នែកនយោបាយ មុនប្រទេសនេះរៀបចំការបោះឆ្នោតជ្រើស តាំងតំណាងរាស្រ្ត នៅខែកក្កដា ឆ្នាំ២០១៣។ ចំពោះបញ្ហានេះ អ្នករាយការណ៍ពិសេស បានស្វាគមន៍ការលើកលែង ទោសដល់លោក សម រង្ស៊ី ប្រធានគណបក្សប្រឆាំងក្នុងប្រទេសកម្ពុជានៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៣ មុនការបោះ ឆ្នោតដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣។ ចំពោះការរីកចម្រើននេះ អ្នករាយការណ៍ពិសេសសង្ឃឹមថា រដ្ឋាភិបាលនឹងចាត់វិធានការចាំបាច់ដើម្បីអនុញ្ញាតឲ្យលោក សម រង្ស៊ី បានចូលធ្វើនយោបាយពេញលេញនៅក្នុងប្រទេសកម្ពុជា និងបានសាទរចំពោះរាជរដ្ឋាភិបាលដែលចាត់វិធានការដ៏មានសារៈសំខាន់នេះ ក្នុងការឈានឆ្ពោះទៅរកការបង្រួបបង្រួម ដែលជាផលប្រយោជន៍នៃប្រជាធិបតេយ្យនីយ កម្មឲ្យកាន់តែមានលក្ខណៈខ្លាំងក្លា និងស៊ីជម្រៅថែម ទៀតនៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែ អ្នករាយការណ៍ ពិសេស នៅតែយល់ឃើញថា វប្បធម៌បង្រួបបង្រួម និងបង្កើតការព្រមព្រៀងលើបញ្ហាសំខាន់ៗ ដែល ជាប្រយោជន៍ជាតិនៅមានភាពទន់ខ្សោយណាស់នៅក្នុងប្រទេសកម្ពុជា។ ប្រទេសនេះ អាចទទួលបានផល ប្រយោជន៍យ៉ាងច្រើន ប្រសិនបើការដឹកនាំបើកចំហទទួលយកមតិយោបល់កាន់តែទូលាយជាងមុន ហើយការ ដែលពុំមានការដឹកនាំបែបនេះ ស្ថានការណ៍នយោបាយនឹងជៀសមិនផុតពីភាពមិនរីកចម្រើន ហើយបាត់ បង់ឱកាសដោយសារគំនិតច្នៃប្រឌិតត្រូវបានរាំងស្ទះ។

៦២. សវិយាបទនយោបាយទូទៅភាគច្រើនហាក់ដូចជាជាប់គាំងរើមិនរួច នាពេលកន្លងមក។ ដើម្បីឲ្យលទ្ធិប្រជាធិបតេយ្យមានដំណើរការសមស្របនៅក្នុងប្រទេសកម្ពុជា ហើយដើម្បីឲ្យវប្បធម៌ប្រជា ធិបតេយ្យចាក់ឫសក្នុងសង្គម អ្នកដែលមានជំហរជាសាធារណៈ ចាំបាច់ត្រូវតែទទួលស្គាល់នូវភាពខ្វះខាត ទើប អាចរកដំណោះស្រាយឃើញ និងអាចទទួលយកបានសំរាប់ភាគីទាំងអស់។ ការសម្រេចបាននូវលទ្ធផលបែប នេះហាក់ដូចជាពុំទាន់មានជាទូទៅនៅក្នុងសង្គម កម្ពុជាបច្ចុប្បន្នឡើយ។ ដូចអ្នករាយការណ៍ពិសេសបានលើកឡើងនៅក្នុងឯកសារផ្សេងដែរ[6] ការរិះគន់ពុំមែនជាបទល្មើសព្រហ្មទណ្ឌទេ ប៉ុន្តែផ្ទុយទៅវិញ វាជាការអនុវត្តសិទ្ធិសេរីភាពបែបមនសិការ វាជាការយល់ឃើញដោយបញ្ញាស្មារតីប៉ុណ្ណោះ។ ទាំងនេះគឺជាលក្ខណៈពិសេសនៃលទ្ធិប្រជាធិបតេយ្យ។ ករណីពុំមានចំណុចទាំងនេះជាមូលហេតុមួយក្នុង ចំណោមមូលហេតុទាំងឡាយដែលប្រទេសកម្ពុជាពុំមានលទ្ធិប្រជាធិបតេយ្យសេរីពេញលេញដូចដែលមានចែងក្នុងនៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសនេះឡើយ។ វាមានសារៈសំខាន់សំរាប់សហគមន៍អន្តរជាតិបន្តជួយព្រះរាជាណាចក្រកម្ពុជា ក្នុងការធ្វើដំណើរលើផ្លូវឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ។ វិធីសាស្រ្តដែលអ្នករាយការណ៍ពិសេសបានស្វែងរក ដើម្បីអនុវត្តអាណត្តិក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិរបស់លោក នៅក្នុងប្រទេសកម្ពុជាគឺជាផ្នែកមួយនៃការខិតខំប្រឹងប្រែង។ លោកមានការសោកស្តាយចំពោះពាក្យសំដីមិនគួរគប្បីដែលបានប្រើមកលើរូបលោកក្នុងរូបភាពជាបុគ្គល បន្ទាប់ពីមានការបោះផ្សាយរបាយការណ៍របស់លោកស្តីពីកំណែទម្រង់ការបោះឆ្នោត និងសម្បទានដី និងចំពោះការតវ៉ាប្រឆាំងនឹងការងារសិទ្ធិមនុស្សរបស់លោកនៅក្នុងប្រទេសនេះ នៅក្នុងដំណើរបេសកកម្ម

[6] សេចក្តីថ្លែងការណ៍ព័ត៌មានរបស់អ្នករាយការណ៍ពិសេសបច្ចុប្បន្ន ដែលបានចេញផ្សាយនៅរាជធានីភ្នំពេញ នៅខាងចុងបញ្ចប់នៃដំណើរបេសកកម្មរបស់លោក ស្វែងរកការពិតអំពីបញ្ហាសិទ្ធិមនុស្សនៅកម្ពុជា នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១។

របស់លោកនៅខែឧសភា ឆ្នាំ ២០១៣។ ទោះជាយ៉ាងណាក៏ដោយ អ្នករាយការណ៍ពិសេស នៅតែប្រកាន់ជំហររឹងមាំរបស់លោកដោយមានជំនឿថា ប្រទេសកម្ពុជាបន្តត្រូវការជំនួយពីការងារក្នុងអាណត្តិរបស់លោក ជាពិសេស មានការសំដែងការគាំទ្រជាច្រើនដល់ការងាររបស់ លោកពីសាធារណជនទូទៅ បន្ទាប់ពីមានការតវ៉ាចុងក្រោយនេះ។

៦៣. វាហាក់ដូចជានៅមានខ្វះការយល់ដឹងសមស្របពីការងារ និងអាណត្តិរបស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិសំរាប់ប្រទេសនេះ។ ប៉ុន្តែ ដំណើរបេសកកម្មក្នុងប្រទេសនេះនៅខែឧសភា ឆ្នាំ២០១៣ មានអត្ថប្រយោជន៍ក្នុងការបង្កើតឲ្យមានឡើងវិញនូវកិច្ចពិភាក្សារវាងអ្នករាយការណ៍ពិសេស និងរដ្ឋាភិបាល ហើយអ្នករាយការណ៍ពិសេស សូមថ្លែងអំណរគុណដល់រដ្ឋាភិបាលដែលបានសហការជាមួយលោក។ លោកទន្ទឹងរង់ចាំដោយក្តីរីករាយក្នុងការបន្តធ្វើការជាមួយរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ផ្សេងទៀត នៅក្នុងប្រទេសកម្ពុជា ដើម្បីឲ្យប្រទេសនេះទទួលបានភាពប្រសើរកាន់តែខ្លាំងថែមទៀត។

៦៤. ជារួបមក ប្រទេសកម្ពុជា បានធ្វើដំណើរលើផ្លូវដ៏វែងមកហើយ ប៉ុន្តែ អ្នករាយការណ៍ពិសេសមានទស្សនៈយល់ឃើញថា នៅតែមានផ្លូវដែលត្រូវធ្វើដំណើរតទៅមុខទៀត ក្នុងការលើកកំពស់ និងការការពារសិទ្ធិមនុស្ស ពង្រឹងអភិបាលកិច្ចល្អ ព្រមទាំងពង្រឹងឯករាជ្យភាព និងសមត្ថភាពរបស់ស្ថាប័នរដ្ឋ ដែលទទួលបន្ទុកលើកកំពស់សិទ្ធិរបស់ប្រជាពលរដ្ឋ។ អាស្រ័យហេតុនេះ អ្នករាយការណ៍ពិសេស សូមអំពាវនាវឲ្យរាជរដ្ឋាភិបាលកម្ពុជា បន្តបោះជំហានទៅមុខក្នុងការអនុវត្តអនុសាសន៍របស់លោកអំពីកំណែទម្រង់ប្រព័ន្ធតុលាការ សភា និងការបោះឆ្នោត ព្រមទាំងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងទៀត។ លោកបានរៀបចំខ្លួនរួចជាស្រេចដើម្បីជួយដោះស្រាយបញ្ហាប្រឈមដែលនៅសេសសល់។

## VIII. អនុសាសន៍

៦៥. រាជរដ្ឋាភិបាល គួរតែប្តេជ្ញាអនុវត្តអនុសាសន៍របស់អ្នករាយការណ៍ពិសេសក្នុងអំឡុងពេលមួយច្បាស់លាស់ដែលកំណត់វិស័យដែលមានការលំបាក និងពាក់ព័ន្ធ។

៦៦. រាជរដ្ឋាភិបាល គួរតែពន្លឿនការអនុវត្តនូវរបៀបវារៈកំណែទម្រង់ស្ថាប័នរដ្ឋ ដែលទទួលបន្ទុកលើកកំពស់សិទ្ធិរបស់ប្រជាពលរដ្ឋ រួមទាំងការអនុម័តច្បាប់គ្រឹះទាំងបី ដែលទាក់ទងនឹងការពង្រឹងឯករាជ្យភាព និងសមត្ថភាពរបស់ស្ថាប័នតុលាការ តាមការសន្យារបស់រាជរដ្ឋាភិបាល។

៦៧. ដោយមិនគិតពីលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ គួរចាត់វិធានការសមស្រប ដើម្បីពង្រឹងឯករាជ្យភាព និងសមត្ថភាពរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីទទួលបានការទុកចិត្ត និងជំនឿពេញលេញពីអ្នកបោះឆ្នោតទាំងអស់នៅក្នុងប្រទេស សំរាប់ការបោះឆ្នោតលើកក្រោយៗទៀត។ ជាពិសេស ចាំបាច់ត្រូវខិតខំ ព្យាយាមខ្លាំងក្លាជាងនេះថែមទៀត ធ្វើយ៉ាងណាឲ្យអ្នកមានសិទ្ធិបោះឆ្នោតទាំងអស់អាចអនុវត្តសិទ្ធិនយោបាយរបស់គេប្រកបដោយអត្ថន័យ។

៦៨. សេរីភាពក្នុងការបញ្ចេញមតិរបស់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងសង្គមកម្ពុជា គួរត្រូវបានគោរព គ្រប់ពេលទាំងអស់ រួមទាំងមុនពេល ក្នុងអំឡុងពេល និងក្រោយពេលបោះឆ្នោត។

៦៩. អ្នកការពារសិទ្ធិមនុស្ស និងជាពិសេស អ្នកដែលការពារសិទ្ធិដីធ្លី គួរតែត្រូវបានអនុញ្ញាតឲ្យបន្ត ការងារ របស់គេ ដោយគ្មានការបំភិតបំភ័យ និងការយាយីរំខាន។

៧០. ការសន្យាថាត្រួតពិនិត្យឡើងវិញលើសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងទៀតដែលមាន ស្រាប់គួរតែធ្វើឡើងជាអាទិភាព និងជាប្រយោជន៍របស់ប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះ ពាល់ដោយសារសម្បទានទាំងនេះគួរតែជាបញ្ហាចម្បងសំរាប់ការត្រួតពិនិត្យឡើងវិញនេះ។

៧១. គួរផ្តល់ការយកចិត្តទុកដាក់ថែមទៀតទៅលើការពង្រឹងសិទ្ធិទទួលបានព័ត៌មាន និងតម្លាភាព ចំពោះបញ្ហាមួយចំនួន រួមទាំងការពិគ្រោះយោបល់ និងការត្រួតពិនិត្យ ស្របតាមអនុសាសន៍ ដែលបានលើកឡើងក្នុងរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការផ្តល់ និងគ្រប់គ្រង សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីផ្សេងទៀត។

៧២. គួរចាត់វិធានការបន្ថែមទៀត ដើម្បីអនុវត្តសិទ្ធិទទួលបានដំណោះស្រាយសមស្រប ទាក់ទងនឹងទំនាស់ដីធ្លីទោះជាធ្វើឡើងតាមរយៈការពង្រឹងយន្តការដោះស្រាយវិវាទផ្លូវការ និង ថ្នាក់ជាតិ ដែលធានាការពង្រឹងការពិនិត្យលើសហគ្រាសពាណិជ្ជកម្មដែលជាភាគីវិវាទ ឬតាម រយៈការពង្រឹងការទប់ស្កាត់កុំឲ្យមានវិវាទកើតឡើងនិងសមត្ថភាពពិគ្រោះយោបល់របស់មន្ត្រី និងកងកម្លាំងប្រដាប់អាវុធក្នុងការដោះស្រាយជាមួយសហគមន៍ដែលរងផលប៉ះពាល់ក្តី។

៧៣. រដ្ឋាភិបាលគួរតែបង្កើតផែនការសកម្មភាពដោយមានកំណត់រយៈពេល ដើម្បីពន្លឿនដំណើរ ការកំណែទម្រង់សភា។

៧៤. រដ្ឋាភិបាល គួរតែពន្លឿនការស៊ើបអង្កេតរឿងក្តីដែលមានពីមុនយូរមកហើយ ដែលពុំទាន់បាន ស៊ើបអង្កេតឲ្យបានសមស្រប ដោយពុំទាន់មានការកាត់ទោសបុគ្គលណាមួយនៅឡើយនោះ។

៧៥. អ្នករាយការណ៍ពិសេស សូមសំដែងសេចក្តីសង្ឃឹមថា គ្រប់គណបក្សនយោបាយទាំងអស់ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នឹងធានាឲ្យការបោះឆ្នោតនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងសន្តិវិធី ដែលគ្រប់ភាគីទាំងអស់ អាចចូលរួមប្រកួតប្រជែងដោយស្មើភាពគ្នា។

------